www.khmerpostusa.com
សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា
KhmerPost USA
Lowell - Lynn - Revere - MA * Providence - Cranston - RI

Free Copies
Vol. 13. Issue #303
Oct 31Th, 2020
Office: 978-677-7163
Direct: 978-656-8141
Email:Khmerpostusa@gmail.com

## ព័ត៌មានសំខាន់ៗខាងក្នុង...

តើហេតុអ្វីបានជាគេចូលចិត្តលេង "ហ្វេសប៊ុក"
សូមអានទៅទំព័រទី ០៨




EU ផ្ដល់ជំនួយសង្គ្រោះបន្ទាន់ជាទឹកប្រាក់ ៤៧ ម៉ឺនដុល្លារអាមេរិកដល់ពលរដ្ឋខ្មែរដែលកំពុងរងវិបត្តិដោយទឹកជំនន់...
សូមអានទៅទំព័រទី ១០




លោក ហ៊ុន សែន ប្រាប់អោយអាជ្ញាធរទាំងអស់...
សូមអានទៅទំព័រទី ១១



ទឹកជំនន់នៅកម្ពុជា ជាឱកាសជួបជុំគ្នា
សូមអានទៅទំព័រទី ១៣



"អ្នកដឹងឬទេ?"

# ដំណឹងចុងក្រោយ: ការបោះឆ្នោតប្រធានាធិបតី







ដោយ: ពិន សំខុន

**របៀបបោះឆ្នោត** នៅចុងអាណត្តិរបស់លោកប្រធានាធិបតី ឌុណល ត្រាំ មកពីគណបក្សជាធារណរដ្ឋ អម ដោយលោក ម៉ាយ ផិន **តទៅទំព័រទី០៣**

# កម្ពុជាប្រតិកម្មនឹងសំណើដកកម្ពុជាចេញពីអាស៊ាន

លោក Bilahari Kausikan អតីតលេខាអចិន្ត្រៃយ៍ក្រសួងការបរទេសសិង្ហបុរី និងបច្ចុប្បន្នជាប្រធានវិទ្យាស្ថានមជ្ឈិមបូព៌ានៅសាកលវិទ្យាល័យជាតិសិង្ហបុរី (NUS) បានលើកសំណើនេះអំឡុងពេលលោកចូលរួមជាវាគ្មិនក្នុងកិច្ចពិភាក្សាមួយកាលពីថ្ងៃសុក្រសប្ដាហ៍មុន។ លោកថា លាវ និងកម្ពុជាកំពុងដើររក "កំហុសនយោបាយ" ច្រំដែល។ ក្នុងន័យនេះ អតីតអ្នកការទូតសិង្ហបុរីដែលធ្លាប់ហៅខ្លួនឯងថា ជាមនុស្ស "ឃើញអ្វីថាហ្នឹង" បរិយាយ

**តទៅទំព័រទី ១២**






មេធាវី លុយ ហាស្កែល LAW OFFICE OF LOUIS S. HASKELL

សេវាកម្មជាទីគាប់ចិត្តចាប់តាំងពីឆ្នាំ 1987

គ្រោះថ្នាក់ចរាចររថយន្តធុនតូច, រថយន្តធុនធំ និងម៉ូតូ • អន្តោប្រវេសន៍
ធ្វើពន្ធ • ការក្ស័យធន • គ្រោះថ្នាក់រអិលដួល • ឆ្កែខាំ
ដំណោះស្រាយ និងការពារបញ្ហាពន្ធដា

សូមអរគុណចំពោះការបន្តនូវទំនុកចិត្តរបស់លោកអ្នកមកលើការិយាល័យមេធាវីយើងខ្ញុំ ក្នុងការដោះស្រាយបញ្ហាផ្នែកច្បាប់ និងពន្ធដារជូនលោកអ្នក ។ យើងខ្ញុំរំពឹងថា នឹងបម្រើលោកអ្នកយ៉ាងល្អនាពេលអនាគត។

បុគ្គលិកយើងខ្ញុំនិយាយភាសាខ្មែរ

Excellent Service Since 1987

Auto, Truck and Motorcycle Accidents
Immigration • Tax • Bankruptcy
Slip & Fall • Dog Bite
Tax Resolution & Defense

Thank you for your continued confidence
In our office to handle your legal and tax matters.
We look forward to serving you well into the future.

LAW OFFICE OF LOUIS S. HASKELL • 16 PINE STREET • LOWELL, MA • (978) 459-8359

16 Pine Street • Lowell, MA • 978-459-8359 • www.attorneyhaskell.com

# មណ្ឌលពិនិត្យសុខភាពឡូវែល

## Lowell Primary Care Center

លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, **M.D.**
**Sokharith Mey, M.D.**

លោក ចាន់ ទូច , **C.N.P.**
**Chhan Touch, C.N.P.**





ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី

**Now Accepting New Patients**

ជំងឺទូទៅ
***Family Medicine***

&

សុខភាពផ្លូវចិត្ត
***Behavioral Health***

អាស័យដ្ឋាន

**1075 Westford Street, Unit 204 • Lowell, MA 01851 • (978) 455-7992**

ទទួលយកម៉ាសហែល, មេឌីឃែរ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

We Accept MassHealth, Medicare and Other Health Insurances
Our Staff Speaks Khmer • Plenty of Free Parking

តមកពីទំព័រទី ០១

# ការបោះឆ្នោតប្រធានាធិបតីនៅអាមេរិក

ជាបេក្ខជនអនុប្រធានាធិបតី, គេនាំគ្នាទៅបោះឆ្នោតសារជាថ្មី ដើម្បីរក្សាប្រធានាធិបតីចាស់ ឬក៏ជ្រើសយកប្រធានាធិបតីថ្មី ដែលអ្នកប្រគួតថ្មីនោះគឺលោក ជោ បាយដិន អម ដោយលោកស្រី កាម្លា ហារីស មកពិខាងគណបក្ស ប្រជាធិបតេយ្យ។

របៀបបោះឆ្នោតគឺ"ការបោះឆ្នោតសាកលមិនចំពោះ Vote Universal Indirct" បានន័យថា ពលរដ្ឋអាមេរីកាំងទាំងអស់ក្នុងរដ្ឋទាំង៥0 ត្រូវអញ្ជើញទៅបោះឆ្នោតឱ្យបេក្ខជនប្រធានាធិបតីទាំង២រូប យកណាមួយដែលខ្លួនពេញចិត្ត, បេក្ខជនដែលបានសម្លេងច្រើនជាងគេ នៅក្នុងរដ្ឋនឹងទទួលបាននូវចំនួន"ដំណាង Delegates"គណបក្សខ្លួនទាំងអស់ ដើម្បីយកទៅរាប់បញ្ចូលក្នុងចំនួនសរុបនៃរដ្ឋក្នុងប្រទេស, បេក្ខជនដែលនឹងបានដំណែងជាប្រធានាធិបតី គឺអ្នកដែលបានចំនួនបូកសរុបទូទាំងប្រទេសនោះ ច្រើនជាងជាង"២៧0ដំណាង" នាថ្ងៃបោះឆ្នោតថ្ងៃអង្គារទី៣ ខែវិច្ឆិកា ២0២0នេះ, ដូចនេះពុំមែនចំនួនឆ្នោតដែលច្រើនជាងគេ កំណត់អ្នកឈ្នះទេ គឺចំនួន"សរុបនៃដំណាង"ទើបជាអ្នកឈ្នះ។

**ស្ថានភាពបច្ចុប្បន្ននៃការបោះឆ្នោត**

លោក ជោ បាយដិន អាយុ៧៦ឆ្នាំ អតីតអនុប្រធានាធិបតីរបស់អូបាម៉ា, មិនធ្វើដូចលោក ខាងណា។

"រដ្ឋទាំង១២ ដែលមិនទាន់ជាក់លាក់"នោះមាន: ណេវ៉ាដាណេ(៦ដំណាង)-អារីហ្សូណា១១-តិកសាស៣៨-អាយ៉ូវ៉ា៦-វិកុងស៊ីង១0-មីជីគ្គាន១៦-អូហាយ៉ូ១៨-ផែស៊ីវេនៀ២0-ណតការ៉ូឡាយណា១៨-ជចជ្យា១៦ នីហ្វ្លរីដា២៩។ តំណាងដែលត្រូវដណ្តើមគ្នាមាន១៨៩។

លោក ឌុណល ត្រាំ អាយុ៧៤ឆ្នាំ បច្ចុប្បន្នជាប្រធានាធិបតី បានខិតខំប្រឹងមិនសម្រាក បើទោះជាលោកទើបនឹងចេញពីពេទ្យដោយសារឆ្លងជម្ងឺ"កូវីដ១៩"ជាមួយភរិយាក៏ដោយ ។ លោកទាក់ទាញបានរដ្ឋចំនួន២0គាំទ្រលោកត្រាំ ដែលប្រកាន់គណបក្សសាធារណរដ្ឋស្រាប់ហើយ សម្លេងគាំទ្របានតែ៤៣% ពីក្រោយគូរប្រកួត។ ប្រធានាធិបតីមុនៗ តែងមានប្រៀបលើគូរប្រកួត សម្រាប់បន្តអាណត្តិទី២ ប៉ុន្តែចំពោះលោក ត្រាំ រងគ្រោះដោយ"កូវិដ១៩"តាំងពី១ឆ្នាំមកហើយ បានត្រូវពលរដ្ឋពិចារណាលើ"ទង្វើជាក់ស្តែង"របស់លោក ពុំមែងលើ"ពាក្យឃោសនា"ដូចមុនទៀតទេ។

រដ្ឋម៉ែន-វែម៉ន-ញូយ៉ក-ម៉ាសាឈូសិត-រ៉ូដអាយឡិន-កូណិកទីកិត-ដែលវែ-ញូជ័រស្ស៊េ-អុីលីណយ-មីនីសូតា-វ៉ាស៊ីនតោនឌីស៊ី-ម៉ែរីឡែន-វៀស៊ីនា-វៀស៊ីនៀខាងកើត-កូឡូរ៉ាដូ-រដ្ឋម៉ុងតាណា(ដំណាង៣)-ដាកូតាខាងជើង៣-ដាកូតាខាងត្បូង៣-អាយដាហូ៤-វ៉ាយូមីង៣-ណេប្រាស្កា៥-កានសាស់៦-មីស៊ូរិ១0-អូក្លាហូម៉ា៧-អាកិនសាស់៦-លូីស្យាណា៨-មីស៊ីស៊ីពី៦-អាឡាបាម៉ា៩-អាកាន់សាស់៦-ថិណេស៊ី១១-សាវការ៉ូឡាយណា៩-កិនទ័រគី៨-វៀស៊ីនៀខាងកើត៥ នឹង អ៊ិនឌីយ៉ាណា១១ ជារដ្ឋ

ពលរដ្ឋនៅរដ្ឋខ្លះ ត្រូវបោះឆ្នោតឱ្យព្រឹទ្ធសមាជិកនឹងឱ្យដំណាងរាស្ត្ររបស់ខ្លួន នាពេលចប់អាណត្តិរបស់ពួកគេដែរ ដូចជានៅ: យូតាហ៏ - ជចជ្យា - ណតការ៉ូឡាយណា-អូក្លាហូម៉ា-ញូមិកស៊ីកូ-មីនីសូតា-អាយ៉ូវ៉ា-កេលីហ្វញ៉ា...។ នេះជារឿងគួរឱ្យស្រៀវសាច់មួយទៀត គឺគណបក្សលោកជោបាយដិន មាន"សម្លេងភាគច្រើន"នៅសភាដំណាងរាស្ត្រជាន់




ប្រពៃណីពណ៌ក្រហម នឹងប្រកាន់យក ត្រាំ-ផែនដែលសម្លេងតំណាងមាន១២៦ ។

ក្នុងចំនួន"ដំណាងធំទាំង៥៣៨-៥៣៨ Delegates" អ្នកឈ្នះជាប្រធានាធិបតី ត្រូវទទួលបាន២៧0សម្លេងយ៉ាងតិច ។ ទោះជាលោក ត្រាំ មាន

ក្រោមរួចហើយ រីឯនៅព្រឹទ្ធសភាវិញ នៅខ្វះតែ៣អាសនៈទៀត នឹងយកបានព្រឹទ្ធសភាជាន់ខ្ពស់ទៀត ។

នាថ្ងៃអង្គារខាងមុខ បើ ជោ បាយដិន ជាប់ជាប្រធានាធិបតីថ្មីនោះ ប្រជាប្រិយភាពគណបក្ស



















ស្រី ហ៊ីឡារី គ្លីងតុន កាលពីឆ្នាំ២0១៦នោះទេ លោកស្រីបានចាញ់ពេលនោះ ក៏ព្រោះតែជឿខ្លាំងពេកទៅលើការស្ទង់មតិ ដែលឱ្យអ្នកស្រីឈ្នះនៅផែនស៊ិវេនៀ- វីកុងស៊ីន-មីឈីគ្គាន់ ថែមទាំងមិនបានទៅឃោសនានៅទីនោះផង, គឺលោក បាយដិន ទៅឃោសនារហូតដល់ចប់ ។ នៅមុន៣ថ្ងៃផ្តាច់ព្រ័ត លោកទទួលបានសម្លេងគាំទ្រ៥៣% ហើយលោកដឹងថា "រដ្ឋ១៩ប្រកាន់យកខាងបាយដិន" រួចហើយ នៅសល់រដ្ឋ១២ទៀតដែលមិនទាន់ច្បាស់ថាយក




ញូមិកស៊ីក-កាលីហ្វ័ញ៉ា-អូរ៉េគ្គាន់ នឹង ស៊ីអេថលជារដ្ឋពណ៌ខៀវ ប្រកាន់ខាង បាយដិន-ហារីស ដែលសម្លេងដំណាងមាន២២៣។

ការគាំទ្រតិចជាង នាម៉ោងចុងក្រោយនេះក្តី ក៏មិនទាន់សម្រេចថាចាញ់ទៅហើយនោះទេ, តាមដំណឹងស្ទង់មតិ គេវិភាគថា: "នៅសល់រដ្ឋ២ដែរ ដែលជាគន្លឹះអាចស្រោចស្រង់ ត្រាំ បាន តែបើលោកត្រាំចាញ់នៅ"ហ្លរីដា"ឬ"ផែស៊ិវេនៀ"ណាមួយនោះ វានឹងបញ្ចប់អាណត្តិប្រធានាធិបតីចាស់ហើយ"។

**បោះឆ្នោតព្រឹទ្ធសមាជិកនឹងសភាដំណាងរាស្ត្រជាមួយគ្នា**

នាថ្ងៃជាមួយគ្នា ទី៣វិច្ឆិការ២0២0 ក៏ប្រជាប្រជាធិបតេយ្យ ក៏ជះចំហាយជួយឱ្យកើនចំនួនព្រឹទ្ធសភាគណបក្សប្រជាធិបតេយ្យបានសម្លេងភាគច្រើននៅសភាជាន់ខ្ពស់ទៀតគឺជាអំណាចដ៏ធំធេង ដែលប្រជាពលរដ្ឋប្រគល់អំណាចដល់គណបក្សប្រជាធិបតេយ្យ: គឺ ១-សេដ្ឋវិមាន ២-ព្រឹទ្ធសភា ៣-សភាដំណាងរាស្ត្រ នៅសល់តែតុលាកំពូល តែ១ប៉ុណ្ណោះ ដែលលោក ឌុណល ត្រាំ បានជួយស្រោចស្រង់ជីវិតរួច យ៉ាងតក់ក្រហល់ នាចុងខែតុលាមុននេះ ។

# នាយឧត្តមសេនីយ៍បាតដៃកង្វក់១២រូប

## ប្រវត្តិរំលោភសិទ្ធិមនុស្សដ៏យូរអង្វែងរបស់នាយឧត្តមសេនីយ៍នៃលោក ហ៊ុន សែន

ផ្តល់សិទ្ធិដោយៈ www.hrw.org/km

**តពីលេខមុន**

មានលោក នេត សាវឿន ជាមន្ត្រី នគរបាលជាន់ខ្ពស់ ហើយឧបករណ៍ សន្តិសុខ នយោបាយរបស់ក្រសួងមហាផ្ទៃពេលនោះមានលោក សុខ ផលជាកម្មាភិបាលសំខាន់មួយរូបនៅទីនោះដែរ។ អំពើរំលោភបំពាននៅក្នុងអំឡុងសម័យអ៊ុនតាក់ (UNTAC) នៅឆ្នាំ១៩៩១ រដ្ឋកម្ពុជា និងហ៊្វុនស៊ិនប៉ិច (FUNCINPEC) ដែលជាក្រុមអ្នកតស៊ូមិនមែនកុម្មុយនិស្តទីពីរ (មួយទៀតគឺរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (KPN-LF) និងក្រុមខ្មែរក្រហម ប៉ុល ពត បាន រួមគ្នាចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដែលជាកិច្ចព្រមព្រៀងមួយស្តីពីដំណោះស្រាយនយោបាយរួមនៃជម្លោះកម្ពុជា។ ក្នុងនោះមានរដ្ឋាភិបាលអន្តរជាតិចំនួន១៨ប្រទេសផ្សេងទៀត ក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះដែរ។ កិច្ចព្រមព្រៀងទីក្រុងប៉ារីសមានចែងអំពីអាណត្តិការងាររបស់អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅប្រទេសកម្ពុជា (ហៅកាត់ថា អ៊ុនតាក់) ដើម្បីរំសាយកម្លាំងប្រដាប់អាវុធនៅតាមតំបន់ភាគច្រើនរបស់កម្ពុជា និងគ្រប់គ្រងផ្ទាល់នូវផ្នែកសំខាន់៧ផ្នែករដ្ឋបាលដែលមានពេលនោះ ដើម្បីបង្កើតបរិយាកាសនយោបាយអព្យាក្រឹតមួយសម្រាប់ឱ្យអង្គការសហប្រជាជាតិរៀបចំការបោះឆ្នោតដែលធ្វើឡើង កាលពីខែឧសភា ឆ្នាំ១៩៩៣នោះ។

នៅក្នុងសម័យអ៊ុនតាក់ប្រវត្តិអ្នកទាំង១២រូប បានពាក់ព័ន្ធច្រើនក្នុងអំពើហិង្សានយោបាយរបស់រដ្ឋកម្ពុជា ដែលរាប់ទាំងឃាតកម្មនយោបាយសំដៅគណបក្សហ៊្វុនស៊ិនប៉ិច និងអ្នកនយោបាយប្រឆាំងអហិង្សាផ្សេងទៀត ហើយកំណត់ទិសដៅធានាឱ្យគណបក្សប្រជាជនកម្ពុជាឈ្នះក្នុងការបោះឆ្នោត ដែលរៀបចំដោយអង្គការសហប្រជាជាតិនៅខែឧសភា ឆ្នាំ១៩៩៣នោះ។ តាមរបាយការណ៍មួយរបស់អ៊ុនតាក់បង្ហាញថា របបរដ្ឋកម្ពុជា ជាអ្នកទទួលខុសត្រូវចំពោះព្រឹត្តិការណ៍



សម្លាប់អ្នកនយោបាយប្រឆាំងចំនួន៣៩ ករណីដែលបានធ្វើឱ្យមានគ្រោះថ្នាក់មនុស្សចំនួន៤៦នាក់ និងការសម្លាប់២៥នាក់ផ្សេងទៀត។ គោលបំណងសំខាន់នៃការសម្លាប់នេះ គឺដើម្បីបំភិតបំភ័យពលរដ្ឋ ហើយមានការសម្លាប់ភ្លាមៗ សរុប៤០នាក់។ របាយការណ៍នោះ ក៏បានរាយបញ្ជីករណីរំលោភបំពានរបស់រដ្ឋកម្ពុជារាប់រយករណីទៀត រួមមានការបាត់ខ្លួនដោយបង្ខំ និងការធ្វើទារុណកម្មផង។ តួលេខនៅក្នុងរបាយការណ៍នេះមិនបានរាយចំនួនករណីរំលោភបំពានឱ្យអស់ទេ ព្រោះអ៊ុនតាក់មិនអាចស៊ើបអង្កេតបានគ្រប់ករណីទេ ឬក៏បញ្ជាក់បានថា នរណាជាអ្នកទទួលខុសត្រូវចំពោះករណីទាំងអស់ ដែលមិនបានស៊ើបអង្កេតនេះដែរ។

ទោះជាយ៉ាងនេះ ក្តីនៅក្នុងការបោះឆ្នោតគណបក្សហ៊្វុនស៊ិនប៉ិចបានឈ្នះលើគណបក្សប្រជាជនកម្ពុជា។ ប៉ុន្តែក្រុមគណបក្សប្រជាជនកម្ពុជា ដែលដឹកនាំដោយលោក ហ៊ុន សែន គំរាមប្រើហិង្សាជំទាស់លទ្ធផលឆ្នោត។ ដោយឈរលើមូលដ្ឋាននេះ គណបក្សប្រជាជប ក៏បានទាមទារដោយជោគជ័យឱ្យអង្គការសហប្រជាជាតិបង្កើតសម្ព័ន្ធភាពសហនាយករដ្ឋមន្ត្រីរវាងហ៊្វុនស៊ិនប៉ិច-ស៊ីភីភី (CPP) ដោយឱ្យសម្តេចក្រុមព្រះជានាយករដ្ឋមន្ត្រីទី១ ហើយលោក ហ៊ុន សែន ជានាយករដ្ឋមន្ត្រី ទី២។ ងារមានន័យខុសគ្នាបន្តិចបន្តួច ប៉ុន្តែម្នាក់ៗមានអំណាចខាងផ្លូវច្បាប់ដូចគ្នា។

ការរំលោភបំពានចាប់តាំងពីសម័យអ៊ុនតាក់(ឆ្នាំ១៩៩៣រហូតមកដល់បច្ចុប្បន្ន)បន្ទាប់ពីអាជ្ញាធរអ៊ុនតាក់ចាកចេញនៅឆ្នាំ១៩៩៣ អំពើហិង្សានយោបាយរបស់គណបក្សប្រជាជនកម្ពុជាបានបញ្ចេញផ្កាភ្លើងម្តងទៀត។ នោះ គឺការប្រឆាំងនឹងអ្នកសារព័ត៌មានរិះគន់ និង គណបក្សជាតិខ្មែរ ដែលទើបបង្កើតថ្មី និងដឹកនាំដោយលោក សម រង្ស៊ី ជាអតីតរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុរបស់គណបក្សហ៊្វុនស៊ិនប៉ិច ត្រូវបានគេកំណត់គោលដៅតាមធ្វើឃាត។ សម្ព័នភាពសហនាយករដ្ឋមន្ត្រី ដែលត្រូវបានរៀបចំឡើងនៅឆ្នាំ ១៩៩៣នោះ បានបញ្ចប់នៅឆ្នាំ១៩៩៧ គឺនៅពេល ដែលលោកហ៊ុនសែនបណ្តេញព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ ចេញពីអំណាចតាមរយៈរដ្ឋប្រហារមួយ។

ភាគច្រើននៃបុគ្គលទាំង១២ រូប បានជាប់ពាក់ព័ន្ធនឹងអំពើហិង្សានយោបាយពីឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៨ ជាពិសេសលោក គន់ គីម, ចាប ភក្តី, ជា ម៉ន, ប៊ុន សេង, ជឿន សុវន្ថា, នេត សាវឿន និង សៅ សុខា។ ភាគច្រើននៃបុគ្គលទាំងនេះ បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងរដ្ឋប្រហាររបស់លោក ហ៊ុន សែន នៅថ្ងៃទី៥ និងទី៦ ខែ កក្កដា ឆ្នាំ ១៩៩៧ ប្រឆាំង ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ដែលជានាយករដ្ឋមន្ត្រី ទី១ និងគណបក្សហ៊្វុនស៊ិនប៉ិចរបស់ព្រះអង្គ។ រដ្ឋប្រហារនេះ បានសម្លាប់សមាជិក ដែលមានភក្តីភាពបំផុត ចំពោះគណបក្សរាជានិយមចំនួនជាង១០០នាក់។ ក្នុងរបាយការណ៍របស់ការិយាល័យសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ខែសីហា ឆ្នាំ១៩៩៧ បានចងក្រងឯកសារអ្នកស្លាប់ថា មានចំនួន៤១នាក់ ហើយថា ចំនួននេះអាចមានដល់៦០នាក់ ដែលត្រូវបានគេសម្លាប់ដោយហេតុផលនយោបាយក្រៅប្រព័ន្ធតុលាការបន្ទាប់ពីរដ្ឋប្រហារហើយ។ តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិសម្រាប់បញ្ហាសិទ្ធិមនុស្សប្រចាំនៅកម្ពុជាលោក ថូម៉ាស ហ៊ែមម៉ាប៊ើគ (Thomas Hammarberg) ថ្លែងក្រោយមកទៀតថា ក្នុងហេតុការណ៍នោះមានមនុស្សរាប់សិបនាក់ ត្រូវគេប្រហារជីវិតភ្លាមៗ ព្រមទាំងករណីឃាតកម្ម និងបាត់ខ្លួនក្រោយរដ្ឋប្រហារ។

ការសម្លាប់នោះ បានបណ្តាលឱ្យអ្នកនយោបាយប្រឆាំង និងសកម្មជននិរទ្ទេសខ្លួនទៅក្រៅប្រទេសដោយសារបារម្ភអំពីអាយុជីវិតរបស់ខ្លួន។ ទោះជាដូច្នេះក្តីអ្នកនយោបាយបានត្រឡប់មកប្រទេសវិញ ក្រោមកិច្ចសម្របសម្រួលចរចាដោយប្រទេសជប៉ុនសហរដ្ឋអាមេរិក និងអង្គការសហប្រជាជាតិ ដើម្បីចូលរួមការបោះឆ្នោតនៅខែកក្កដា ឆ្នាំ១៩៩៨ ដែលជាដំណើរការបោះឆ្នោតមួយប្រកបដោយអំពើហិង្សា និងមានគុណវិបត្តិ។

រដ្ឋប្រហារឆ្នាំ១៩៩៧ និងសន្លឹកឆ្នោតនៅឆ្នាំ១៩៩៨នោះ **តទៅទំព័រទី០៥**



តមកពីទំព័រទី ០៤

# នាយឧត្តមសេនីយ៍បាតដៃកង្វក់១២រូប

បានបន្តឱ្យមានការបោះឆ្នោតរដ្ឋសភា ក្រោមអំណាចត្រួតត្រា និងការបន្លំរបស់គណបក្ស ប្រជាជនកម្ពុជានៅឆ្នាំ២០០៣, ២០០៨ និង ឆ្នាំ២០១៣។គណបក្សប្រជាជនកម្ពុជាអះអាង ថា ខ្លួនបានឈ្នះដោយពិតប្រាកដ ពេលដែល គណបក្សកាន់អំណាចមួយនេះ បានបន្សាប ឥទ្ធិពលគណបក្សហ៊្វុនស៊ិនប៉ិច ហើយផ្តល់ សម្ប ទាននយោបាយឱ្យវិញ ខ្លះក្នុងពេល ដែលជីវិត នយោបាយរបស់គណបក្សនេះបម្រុងនឹងស្លាប់ ទៅហើយនោះ។

ទង្វើរបស់លោក ហ៊ុន សែន និងគណបក្ស ប្រជាជនកម្ពុជាមិនបានក្លាយជាឧបសគ្គ ឬប៉ះ ពាល់ដល់ការត្រួតត្រារបស់លោក ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជាទេ។ ហើយបញ្ហា នេះ ក៏មិនបានបញ្ឈប់ពួកគេពីការពឹងផ្អែកលើ ការលួតលាស់អំណាចសេដ្ឋកិច្ច តាមរយៈក្រុម អ្នកមានអំណាច រឹប អូស ដីធ្លី និងការកេង ប្រវ័ញ្ចលើកម្មកររោងចក្រ ដែលមានប្រាក់ខែ តិចនោះដែរ។ពីឆ្នាំ១៩៩៨ មកដល់ឆ្នាំ ២០០៨ ឧបសគ្គចំពោះលោក ហ៊ុន សែន និង គណបក្ស ប្រជាជនកម្ពុជា ផ្នែកនយោបាយ គឺការលេច ចេញវត្តមានប្រជាប្រិយភាពរបស់គណបក្ស សម រង្ស៊ី (SRP) ដែលចេះ តែរីកធំឡើង។ គណបក្ស សម រង្ស៊ី ចេះតែកើនឡើងប្រជាប្រិយ ភាព តាមរយៈចូលរួមធ្វើបាតុកម្មប្រឆាំង នឹង ការបាត់បង់ ដីធ្លី ផ្ទះសម្បែង ហើយភាគច្រើន សហជីពកម្មករដឹកនាំការធ្វើកូដកម្មទាមទារប្រាក់ ឈ្នួល និងលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ។

ក្នុងឆ្នាំ២០១២ លោក សម រង្ស៊ី និង កឹម សុខា ដែលជាប្រធានគណបក្សសិទ្ធិមនុស្សបាន ច្របាច់បញ្ចូលគ្នាទៅជាគណបក្សសង្គ្រោះជាតិ (CNRP) មួយ ដើម្បីប្រកួតជាមួយគណបក្ស ប្រជាជនកម្ពុជាក្នុងការបោះឆ្នោតនៅឆ្នាំ២០១៣។ ការបោះឆ្នោតនេះ មានលក្ខណៈមិនប្រក្រតីជា ប្រព័ន្ធ ហើយក៏មិនសេរី និងយុត្តិធម៌ដែរ។ គណបក្សប្រជាជនកម្ពុជាអះអាងពីជ័យជម្នះ បន្តិចបន្តួច (ប្រកៀកប្រកិតគ្នា) ដែលធ្វើឱ្យ លោក ហ៊ុន សែន នៅកាន់អំណាចដដែល។

កំណែទម្រង់កងកម្លាំង សន្តិសុខ ដែលមាន និន្នាការនយោបាយពិតជាទៅមិនរួចលោក ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជារឹតតែ ពឹងផ្អែកលើមេបញ្ជាការទាំង១២រូប និងមេ បញ្ជាការជាន់ខ្ពស់ផ្សេងទៀត នៅក្នុងកងកម្លាំង យោធារាជអាវុធហត្ថ និងនគរបាល ដែលជា ប្រធានបទនៃរបាយការណ៍នេះ។ និន្នាការនេះ ត្រូវបានគូសបញ្ជាក់យ៉ាងច្បាស់ក្នុងមហាសន្និបាត របស់គណបក្សប្រជាជនកម្ពុជានៅឆ្នាំ២០១៥ ជាពិសេសការកើនឡើងចំនួនមេបញ្ជាការកង កម្លាំង សន្តិសុខ ឬកងប្រដាប់អាវុធ និងមន្ត្រី រដ្ឋាភិបាលផ្សេងទៀត ដែលទទួលបន្ទុកផ្នែក សន្តិសុខនៅក្នុងគណៈកម្មាធិការកណ្តាលរបស់ គណបក្សប្រជាជនកម្ពុជា (សូមមើល ឧបសម្ព័ន្ធទី ១)។ តាមការគណនារបស់អង្គការឃ្លាំមើល សិទ្ធិមនុស្ស (Human Rights Watch) យ៉ាង ហោចណាស់មានមន្ត្រី៨០រូប ត្រូវបានគេបញ្ចូល បន្ថែម។ នៅមហាសន្និបាតបក្សក្នុងខែមករា ឆ្នាំ២០១៨ ដែលត្រូវអនុម័តផែនការបក្ស សម្រាប់ការបោះឆ្នោតជាតិឆ្នាំ២០១៨ ក៏មាន បញ្ចូលបុគ្គលិកនៃកងកម្លាំងសន្តិសុខសន្ទឹក សន្ធាប់ដែរ។ ក្នុងនោះ គឺមានមន្ត្រីយោធា៦៤ នាក់ភាគច្រើនជាថ្នាក់ឧត្តមសេនីយ៍ទោនេះ បើ តាមឯកសារដែលអង្គការឃ្លាំមើលសិទ្ធិមនុស្ស បានឃើញ។

លោក ហ៊ុន សែន បានប្រកាស "ការ ប្តេជ្ញាចិត្តដាច់ខាត" រក្សាស្ថិរភាពសណ្តាប់ធ្នាប់ នយោបាយនៅកម្ពុជា ដើម្បីឱ្យគាត់អាចក្លាយ ជានាយករដ្ឋមន្ត្រីបន្តទៀត នៅបន្ទាប់ពីការបោះ ឆ្នោត ដែលកំណត់ធ្វើនៅឆ្នាំ២០១៨។ យោង តាមប្រវត្តិពីអតីតកាលនិងតួនាទីបច្ចុប្បន្នកាល របស់ពួកគេ គឺថា លោក ហ៊ុន សែន ពឹងផ្អែក លើមេបញ្ជាការទាំង១២រូបនេះ និងកូនចៅ របស់ពួក គេដើម្បីប្រព្រឹត្តអំពើរំលោភសិទ្ធិ មនុស្សនៅពេលណាចាំបាច់សម្រាប់តែអំណាច និងផលប្រយោជន៍សេដ្ឋកិច្ចរបស់ពួកគេ។ ភាព គ្រោះថ្នាក់នេះ គឺបានឆ្លុះបញ្ចាំងទាំងតាមរយៈ កំណត់ត្រាសកម្មភាពរំលោភបំពានសិទ្ធិមនុស្ស របស់ពួកគេយូរមក ហើយក៏ដូចជាក្នុងបរិបទ នៃការបោះឆ្នោតឆ្នាំ២០១៣ និងការបោះឆ្នោត ដែលកំណត់ធ្វើនៅឆ្នាំ២០១៨ដែរ។ មហាបាតុ កម្មដោយសន្តិវិធីបានកើតមានក្រោយការបោះ ឆ្នោតឆ្នាំ២០១៣ ប្រឆាំងការបន្លំសន្លឹកឆ្នោត ដោយគណបក្សប្រជាជនកម្ពុជា ហើយការធ្វើ កូដកម្មទ្រង់ទ្រាយធំថ្មី ទាមទារឱ្យដំឡើងប្រាក់ ឈ្នួល ក៏បានកើតឡើងដែរ។ ការប៉ុនប៉ងទាំង កំរោលរបស់កងកម្លាំងសន្តិសុខ ដើម្បីទប់ស្កាត់ និងបង្ក្រាបការប្រមូលផ្តុំទាំងនេះជួនកាលបង្ក ឱ្យសង្គមវឹកវរ ដែលធ្វើឱ្យកងសន្តិសុខលើក យកជាមូលហេតុ ដើម្បីឆ្លើយតបភាពវឹកវរនោះ ដោយអំពើហិង្សាហួសហេតុរួមមានទាំងការ ប្រើកម្លាំងមិនចាំបាច់ ដែលបណ្តាលបាត់បង់ ជីវិតមនុស្ស។ ជាលទ្ធផលមានមនុស្សស្លាប់ចំនួន ៧នាក់ នៅដើមឆ្នាំ២០១៤។ គណបក្សប្រជា ជនកម្ពុជាថ្កោលទោសការតវ៉ា និងកូដកម្មទាំង នោះថា ជាផែនការរបស់គណបក្សសង្គ្រោះជាតិ (CNRP) ញុះញង់ឱ្យមាន "បដិវត្តពណ៌"។

**តទៅទំព័រទី ១២**






# Cambodia Opposition Party Perseveres In Face Of Hun Sen Crackdown

*October 28, 2020 in Cambodia / Conflict / Current Events by Ian D'Elia (updated on October 28, 2020)*

Despite a widening crackdown on dissent by the Cambodian People's Party (CPP), the opposition Cambodian National Rescue Party (CNRP) persists, and with it the country's abiding hope for democracy. For nearly three years, the CPP has been carrying out an aggressive, systematic campaign to wipe out all political opposition and cling to rule over Cambodia. The CPP has targeted not only members and supporters of the CNRP, but also human rights and democracy activists, leaving the future of Cambodian politics highly uncertain.

The CPP, led by current Prime Minister Hun Sen, has been in power for four decades. In the 2013 general election, the then-new CNRP nearly ousted the CPP from power. The historic near-victory led to months of mass protests demanding that the long-standing CPP step down. Once the protests stopped, the country experienced a period of relative calm until 2017, when commune elections revealed that the CNRP had the support to succeed in the 2018 general election. In an effort to avoid the threat posed by the CNRP in 2013, the CPP began their campaign to eliminate opposition, which continues to this day.




On September 3rd, 2017, the CPP arrested CNRP president Kem Sokha. Sokha was accused of collaborating with the United States (US) to overthrow the CPP and subsequently charged with treason, according to Al Jazeera. A number of human rights organizations, including Amnesty International and Human Rights Watch, have condemned the arrest as "bogus." Cambodia expert Katrin Travouillon stated that "the charges against Sokha … [have] been rejected as baseless by pretty much anyone outside of the Cambodian government." In November 2017, the CPP forcibly dissolved the CNRP, and has since targeted, jailed, and exiled many members and supporters of the party. Over the last few years in Cambodia, desperate cries for a better democracy have become commonplace.

The state of Cambodia's economy has proven detrimental to its political stability. With China overtaking the European Union (EU) as Cambodia's primary source of aid and investment, economic leverage from Western states on democracy and human rights issues has become increasingly weak. In February, the EU partially suspended Cambodia's preferential trade benefits but failed to compel the CPP to release Sokha and end the crackdown, writes Al Jazeera. Moreover, according to Professor Sophal Ear of Occidental College, China's support, alongside the COVID-19 pandemic, is doing "immeasurable" harm to the Cambodian economy, contributing to the country's growing sense of desperation.

From mid-2020 on, the CPP's crackdown has come to target not only CNRP members, but also human rights and democracy activists. Kem Monovithya, daughter of Sokha, said the CPP has adopted blanket repression to stop "a spark from becoming fire" because "they can't handle competition in free and fair elections."

In late July, the number of arrests spiked following the seizure of well-known human rights activist Rong Chhun, who was accused by the CPP of spreading "fake news," according to Al Jazeera. In response to the rise in arrests, Phil Robertson of Human Rights Watch stated that "the government … is trying to intimidate the remaining CNRP members into silence."

**Continued to Page 07**






Continued from page 06

# Cambodia Opposition Party Perseveres In Face Of Hun Sen Crackdown

As of late September, more than 140 CNRP activists have been arrested. Among them is former CNRP member Kong Sam An, who was sentenced alongside five others to seven years in prison for allegedly plotting to overthrow the CPP. Mere minutes after the sentence, a video was released online of Kong's daughter Mouyly outside a provincial court pleading: "My father is not guilty. Please, NGOs, help us."

Altogether, the CPP has made clear its objective to eradicate the CNRP. CPP spokesman Sok Eysan stated that "there [has been] no future for [the] CNRP since November 16, 2017. CNRP's supporters, if they continue to support the party, continue to stay in jail."

The bleak reality that Cambodia has been effectively transformed into a one-party state casts doubt on the future of the CNRP — and of democracy and human rights — in the country. Yet hope still shines through. Professor Ear of Occidental College holds that "the CNRP, whether it is there or not, still holds an idea that cannot be extinguished. As long as one person still believes in the idea that the Cambodian government cannot simply run roughshod of human rights, democracy, and freedom, there is hope."

This hope will be what guides Cambodia's upcoming pursuit for democracy and human rights. All those who have remained hopeful must organize peaceful protests against the CPP. In doing so, they must demand not only that all of the arrested activists and CNRP members be freed, but also that the next general election is monitored by international organizations widely considered legitimate purveyors of democratic norms. The greater the number of protestors, the more difficult it will be for the CNRP to repress the resistance, and the more likely that the international community will confer legitimacy upon the transition to ensure long-lasting peace.






មណ្ឌលពិនិត្យសុខភាពលីន

**Lynn Primary Care Center**

លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.

**Sokharith Mey, M.D.**

ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី

Now Accepting New Patients

អាស័យដ្ឋាន

280 Union Street, Unit 402 • Lynn, MA 01901 • (781) 780-7755

ទទួលយកម៉ាសហែល, មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

ជំងឺទូទៅ

***Family Medicine***

សុខភាពផ្លូវចិត្ត

***Behavioral Health***

We Accept MassHealth, Medicare and Other Health Insurances
Our Staff Speaks Khmer

"អ្នកដឹងឬទេ?"

# តើហេតុអ្វីបានជាគេចូលចិត្តលេង"ហ្វេសប៊ុក"

ដោយ ពិន សំខុន

ហ្វេសប៊ុកជាមធ្យោបាយទំនាក់ទំនង

ហ្វេសប៊ុកជាសហគ្រាសនឹងឯកជនមួយ ដែលមានប្រជាប្រិយបំផុត ដែលធ្វើឱ្យមនុស្សទាំងតូចទាំងធំជួបអ្នកដ៏ទៃ ឬក៏រកពតិមានដែលខ្លួនចង់បាននោះឃើញ ។ អ្នកប្រើប្រាស់ចូលចិត្តប្រើវាតាមទូរស័ព្ទ ឬតាម"អាយផាត" ឬតាម"ឡាបតុប"ឬក៏តាមទូរស័ព្ទសម្រាប់ទាក់ទងគ្នា, បង្ហាញពីគំនិត,បង្ហាញពីស្នាដៃ, បង្ហាញពីរូបថត...ទៅវិញទៅមក ។ អ្នកដែលមានសម្ភារៈអេឡិកត្រូនិកទាំងនោះ តែងដាក់កម្មវិធី"ហ្វេសប៊ុក"បញ្ចូល ដើម្បីឱ្យបានប្រើនូវទំនាក់ទំនង ពីមនុស្សឆ្ងាយជិត ដោយមិនរើសមុខ ។

អ្នកប្រើប្រាស់ហ្វេសប៊ុកម្នាក់ៗ អាចមានទំនាក់ទំនងជាមួយមនុស្សពី១០-២០នាក់ ខ្លះអាចដល់រាប់ពាន់ ឬក៏ដល់លាននាក់ថែមទៀត ចំណែកឯក្រុមហ៊ុនហ្វេសប៊ុកវិញ ក៏បានធ្វើការងារភ្ជាប់ទំនាក់ទំនងឱ្យមនុស្សរាប់រយលាននាក់ ដែលនេះហើយជាមធ្យោបាយដ៏សំខាន់សំរាប់រកប្រាក់ចំណូលឱ្យសហគ្រាសនី តាមរយៈការផ្សាយពាណិជ្ជកម្មខ្លីៗ ឬវែងៗ ជូនទៅដល់មនុស្សរាប់សែនលាននាក់ទាំងនោះ ។

ដូចគ្នានឹងហ្វេសប៊ុក គេក៏ឃើញសហគ្រាសន្តី យូទូប YouTube , ទ្វីទ័រ Twitter".នឹងមួយចំនួនទៀត មានសកម្មភាពពាណិជ្ជកម្មដ៏មានប្រជាប្រិយភាពដូចគ្នានេះដែរ, មានបុគ្គលិកធ្វើការរាប់ពាន់នាក់វិនិយោគធនធានរាប់រយលានដុល្លាដូចគ្នា ដើម្បីបំរើប្រជាប្រិយភាពពង្រឹងភាពចូលចិត្តរបស់អតិថិជន ធ្វើឱ្យអ្នកប្រើប្រាស់រឹតតែមានទំនាក់ទំនងកាន់តែច្រើន នឹងរិតតែល្បីឈ្មោះ ។ គេបានហៅសហគ្រាសន៏ទាំងនោះថា "ប្រព័ន្ធផ្សព្វផ្សាយសង្គម Social Media" ពីព្រោះតែបានបំរើសង្គមដោយការផ្សព្វផ្សាយសេរីជាប្រយោជន៏មហាជន ។ គេបានបង្រៀនមនុស្សឱ្យចេះប្រើធនធានទាំងនោះ ដោយឥតគិតថ្លៃ ដែលទំនាក់ទំនងទាំងឡាយនោះបណ្ដាលឱ្យអ្នកប្រើប្រាស់វា បង្កើនសមត្ថភាពជាអ្នកមានចំណេះខ្ពស់ ជាអ្នកជួយសង្គ្រោះនឹងជាអ្នកមានអំណាចច្រើន ។

### ហ្វេសប៊ុកបានប្ដូរសង្គមជាទំនើប

អស្ចារ្យណាស់ មិនថាតែក្មេងៗទេដែលកាន់ទូរស័ព្ទយ៉ាងសង្ហារបង្អួតគ្នា ព្រោះតែរហ័សរហួនស្មារតីនៅខ្សៀវខ្លា ឥឡូវសូម្បីតែចាស់ៗតាៗយាយៗ ដែលគេស្មានថា"អស់សមត្ថភាពនឹងអួតអាងទៅហើយ"នោះ ក៏មានទូរស័ព្ទដ៏សង្ហារនោះដែរ ។ កាន់ទូរស័ព្ទដៃបង្គុយជុំគ្នាតែមិនមានពេលនិយាយរកគ្នាទេ ប៉ុន្តែម្នាក់ៗផ្ដោតអារម្មណ៍តែទៅលើទូរស័ព្ទរបស់ខ្លួនទៅវិញ សូម្បីតែដើរក៏ដូចគ្នាដើរស្មើរតែជល់ឡាន ជល់ម៉ូតូ ព្រោះរវល់តែសម្លឹងទៅទូរស័ព្ទដៃខ្លួននោះ ។ ដូច្នេះការរកលុយបំរើ"របស់ចាំបាច់បំផុត"ជាមុននោះ គឺទិញទូរស័ព្ទដៃ ដែលមានតម្លៃរាប់រយដុល្លារ ពុំមែនទិញម្ហូបអាហារទៀតទេ ។

កុមារតូចៗ ក៏ដូចគ្នា ឪពុកម្ដាយទិញ "អាយផាត" បំពេញចិត្តកូន នាថ្ងៃខួបកំណើត កូនលេង "អាយផាត"នោះមិនឈប់ឈរ ភ្លេចបាយទាំងភ្លេចទឹក មិនខិតខំរឿនសូត្រអ្វីទៀតទេ កម្មវិធីក្នុង "អាយផាត"របស់គេ គួរឱ្យចូលចិត្តខ្លាំងណាស់ ថែមពីនោះទៅទៀត ម្ដាយឪពុក ភ្ជាប់ទំនាក់ទំនង




មិនជាប់ប្រដៅកូនខ្លួនឯង ក៏លែងបានទៀតផង ។ មានកម្មវិធីសម្រាប់កុមារ ឬសម្រាប់មនុស្ស ជំទង់ដែលជាល្បែងប្រជែងបញ្ញាដ៏ឈ្លៀសវៃរបស់ក្មេងៗ ដែលចាស់ៗ តាមដេញប្រាជ្ញាមិនទាន់ទេ ។ ឥឡូវនៅសាលារៀន ឱកាសមាន"កូវីដ១៩" គ្រូតម្រូវឱ្យសិស្សមាន"សម្ភារៈអេឡិកត្រូនិក"សម្រាប់ភ្ជាប់ថ្នាក់រៀន ទៅនឹងផ្ទះ គឺវាសំខាន់ណាស់សម្រាប់ "រៀននៅផ្ទះ"តែម្ដង ដោយកាពារកុំឱ្យឆ្លងជម្ងឺ ។

អ្នកនយោបាយ ក៏ដូចជាអ្នករកស៊ី គេប្រើមធ្យោបាយ"ទំនាក់ទំនងសង្គម"ដ៏អស្ចារ្យនេះ សម្រាប់ធ្វើការឃោសនាមហាជន ឱ្យបានជួបមនុស្សជាច្រើន ដោយចំណាយធនធានតែបន្តិចបន្តួច... មធ្យោបាយនេះ មានប្រសិទ្ធិភាពច្រើនណាស់ ពីព្រោះគេអាចផ្ដល់ព័ត៌មានថ្មីៗ បានយ៉ាងឆាប់រហ័ស ហើយគេក៏អាចប្ដូរជំនឿមនុស្សទៅជាមួយនឹងព័ត៌មានដែលគេបានបញ្ជូនទៅឱ្យអ្នកទទួលបានជាមួយគ្នានោះដែរ ។

### តើ"ហ្វេសប៊ុក"ធ្វើអ្វីខ្លះដើម្បីឱ្យគេចង់ប្រើខ្លួន?

គឺប្រាកដជាមិនមែនចៃដន្យទេ ដែលមនុស្សទូទាំងពិភពលោកចូលចិត្តប្រើ"ប្រព័ន្ធផ្សព្វផ្សាយសង្គម"ទាំងឡាយនោះ ។ យើងបាននិយាយហើយថា ក្រុមហ៊ុនទាំងនោះ បានវិនិយោគលុយច្រើនសន្ធឹកណាស់ដើម្បីបង្កើតបានជាប្រព័ន្ធទាក់ទងមនុស្សដ៏មានប្រជាប្រិយភាពហើយប្រើបុគ្គលិកច្រើនពាន់ម៉ឺននាក់នោះ ។ មេដឹកនាំរបស់សហគ្រាសន៏ទាំងនោះ គេគិតថា "គេនឹងរកលុយបាន ដោយសារតែមនុស្សត្រូវការទាក់ទងគ្នាត្រូវការគំនិតដ៏ច្រើនរួមគ្នានឹងត្រតូវការអំណាច...." ។

ម៉ាស៊ីនធំៗ សម្រាប់បញ្ជូនកម្មវិធីបង្កើត"ហ្វេសប៊ុក" បង្រៀនឱ្យចេះប្រើ ហើយណែនាំឱ្យប្រើសម្ភារៈទំនើបនោះ បានទៅតាមចំណង់នៃអ្នកប្រើបានត្រូវបង្កើតឡើង ។ ម៉ាស៊ីនដដែលនោះ បានកត់ត្រាសកម្មភាពប្រើប្រាស់បណ្ដាញ"ហ្វេសប៊ុក" របស់អ្នកប្រើគ្រប់គ្រប់គ្នាក្នុង"ប្រព័ន្ធចងចាំ"ដ៏ធំធេងរបស់គេ ។ ការសិក្សាទៅលើការចងចាំពីលក្ខណៈសម្បត្តិរបស់អតិថិជនថា "តើម្នាក់នោះចូលចិត្តអ្វី? - តើអ្នកនោះត្រូវការអ្វីទៀតដើម្បីដើរទៅរកគោលដៅគេបាន? - តើ"ហ្វេប៊ុក"ត្រូវធ្វើអ្វីដើម្បីជាជំនួយដល់វត្ថុបំណងរបស់ភ្ញៀវ? - នៅលើសំនួរទាំងនោះ "បុគ្គលិកនឹងម៉ាស៊ីនហ្វេសប៊ុក" ដ៏ស្មុគស្មាញ ក៏បញ្ចេញស្នាដៃប្រមូលអ្នកដែលចូល



ចិត្តចុច"Like" ឬក៏ខ្លាំងជាងនេះទៅទៀតចុច"Share" ផ្ដល់ជាទំនាក់ទំនងត្រឡប់មកម្ចាស់ដើមវិញ ។ ដូច្នេះមានសុទ្ធតែមនុស្សដែលមានចំណូលចិត្តដូចយើង ឬក៏ប្រហាក់ប្រហែលគ្នា ដែលធ្វើឱ្យយើងគិតថាអាចនឹងចូលចិត្តនឹងយើងបាន, ធ្វើឱ្យយើងចង់ចូលទៅក្នុងទំព័រផ្សព្វផ្សាយរបស់គេ ដែលក្នុងនោះមានមនុស្សច្រើនទៀត ដែលយើងអាចនឹងត្រូវការជួបគ្នា នេះជាចំណងមិត្តភាពថ្មី ជាមួយមនុស្សដ៏ច្រើនបន្តរបន្ទាប់ ដែលយើងមិនដែលស្គាល់ពីមុនមក ។

អ្នកប្រើប្រព័ន្ធហ្វេសប៊ុកទាំងអស់ តែងតែទទួលផលដូចគ្នា គឺបានទទួលស្គាល់មនុស្សដែលខ្លួនបានបង្ហាញថា"ចូលចិត្តនឹងឃើញ ដោយចង់ប្រាស្រ័យទាក់ទង" ខាងចុងម្ខាងទៀត ក៏អាចមានបំណងដូចគ្នាដែរ, ប៉ុន្តែបើមិនចង់ ឬមិនពេញចិត្តទៅវិញ អាចលប់ចោលដោយខ្លួនឯងក៏បានដែរ ។ ចំណងនេះបានពង្រីកទំនាក់ទំនងកាន់តែ ធំទៅៗគ្មានទិបញ្ចប់បាន... ដែល"ហ្វេសប៊ុក"ខិតខំបង្កើតកម្មវិធីកាន់តែច្រើន កាន់តែថ្មី កាន់តែប្រណិត ផ្ដល់ផលប្រយោជន៏ឥតគណនា ដល់អ្នកប្រើប្រាស់ រហូតដល់ទៅ"ញៀនហ្វេសប៊ុក"អត់វាមិនបាន ។

### គុណសម្បត្តិហ្វេសប៊ុកក៏មានគុណវិបត្តិវាដែរ

នៅពេលដែលយើងឃើញកូនចៅយើងលេងហ្វេសប៊ុកមិនឈប់បណ្ដាលឱ្យពួកគេនិយាយពាក្យអសុរស ជួបកាលដេកក៏មិនបានគ្រប់គ្រាន់ បរិភោគក៏មើលមុខប្ដូបថា ឆ្ងាញ់ ឬអត់, ទាំងនេះ ធ្វើឱ្យឪពុកម្ដាយព្រួយបារម្ភជាខ្លាំង ចំពោះសុខភាពកូនចំពោះអកប្បកិរិយាឆ្មើងឆ្មៃរបស់កូន... នេះជាបញ្ហារបស់មនុស្សជាឪពុកម្ដាយ ដែលត្រូវរកវិធីមកអប់រំកូនសារជាថ្មី ពុំមែនជាបញ្ហារបស់ហ្វេសប៊ុកទេ ពីព្រោះគេបានបំពេញបំណងនៃច្បាប់ទម្លាប់រួចហើយ ។

ជូនកាលហ្វេសប៊ុក បង្ហាញនូវរឿងដែលយើងបានប្រព្រឹត្តមិនគប្បី បណ្ដាលឱ្យទៅជាអាម៉ាស, ពេលខ្លះរឿងកំប្លែងដែលមិនទូលខុសត្រូវ ក៏ក្លាយជាការយល់ច្រឡំ, ពេលខ្លះអ្នកយករូបថតអ្នកដ៏ទៃមកមកផ្សាយ វាប៉ះពាល់ដល់សិទ្ធិអ្នកដ៏ទៃ, អ្នកខ្លះទៀតប្រើហ្វេសប៊ុកសម្រាប់ជេរប្រទេសផ្ដាសារគ្នា ដែលអ្នកប្រើខ្លះមិនបានយល់ថា: ជា"ប្រព័ន្ធផ្សព្វផ្សាយ"មួយ ដែលត្រូវមានលក្ខខណ្ឌសម្រាប់ប្រើប្រាស់វា បើមិនដូច្នោះទេ ហ្វេកប៊ុកនឹងគ្មានសណ្ដាប់ធ្នាប់បាត់បង់ប្រជាប្រិយភាពនឹងខ្វះប្រាក់ចំណូល...ហេតុនេះហើយបានជាហ្វេសប៊ុកបានដាក់ទណ្ឌកម្មដោយធ្វើឱ្យគាំងកម្មវិធិជាញឹកញាប់ ។

នៅពេលឃើញអ្នកនយោបាយធ្វើការទាក់ទងទាញយកសហគមន៏ណាមួយជាសមាជិក គេតែងតែ"Like"ឬក៏"Share"អត្ថបទនឹងរឿងរ៉ាវ ដែលគេទទួលបានពីនរណាម្នាក់ទៀតនៅក្នុងបណ្ដាញ ។ អត្ថបទទាំងនោះ បានផ្ដល់នូវជំនឿទុកចិត្ត មុននឹងយើងបន្តចែករំលែកដល់អ្នកឯទៀតដែលយើងបានសន្មត់ថា ជាមិត្ត ហើយមានការឆ្លើយឆ្លងគ្នាលើកទឹកចិត្តគ្នាទៅវិញទៅមក ។ ទំនាក់ទំនងនេះហ្វេសប៊ុក បានផ្ដល់ឱ្យអ្នកប្រើប្រាស់នូវ សន្តិសុខជុំវិញខ្លួន ភាពរឹងប៉ឹងនៃគំនិតក្នុងក្រុមរបស់ខ្លួន ទប់ទល់នឹងអ្នកមិនយល់ស្របគ្នាដែលជាក្រុមមួយទៀត ។ ក្រុមនិមួយៗអាចនឹងរីកចំរើនធំឡើងរៀងខ្លួន តែមិនចូលគ្នាទេ ពីព្រោះតែម្នាក់ៗមានជំនឿយ៉ាងមុតមាំថា"ខ្លួនឯងជាអ្នកធ្វើត្រូវគិតត្រូវជាង" ហើយជូនកាល ក៏ខ្លាយទៅជាជម្លោះរវាងក្រុមគ្នាឯង ក៏មាន ។

### ហ្វេសប៊ុកជាប្រព័ន្ធ"ញាក់ខ្សែ"ដល់អ្នកប្រើប្រាស់ឬ?

"ញាក់ខ្សែ, ប្រើប្រាស់, ឬញុសញង់" គឺជាអំពើដែលមិនស្របច្បាប់ ដែលហ្វេសប៊ុកមិនបានធ្វើ ឬក៏ធ្វើដោយគ្មានបំណងទេ, ប្រព័ន្ធហ្វេសប៊ុកពុំមែនជាប្រព័ន្ធដែលទទួលខុសត្រូវដូចកាសែត ឬវិទ្យុ-ទូរទស្សន៏ទេ, អ្វីទាំងអស់បានកើតចេញពីការចង់ដោយអ្នកប្រើខ្លួនឯង ដែលខិតខំរតព័ត៌មានក្នុងហ្វេសប៊ុកយកមកប្រើដោយខ្លួនឯងទៀត, ក៏ប៉ុន្តែលទ្ធផលអវិជ្ជមាន ដូចជាធ្វើឱ្យក្មេងចាស់"ញៀន"ល្បែង ឬលេងឥតឈប់ឈរ គឺ"ជាកំហុសមិនចំពោះ"របស់ហ្វេសប៊ុក ដែលថ្នាក់ដឹកនាំគេខិតខំស្វែងរកការខ្វះខាតជារៀងរាល់ថ្ងៃថែមទៀត ។

### មធ្យោបាយការពារ

ដើម្បីទប់ស្កាត់ការភ្លាត់ស្នៀតដូចដែលបានរៀបរាប់ ដ៏ប្រសើរ គឺ ១-សម្រាប់ក្មេងៗ ត្រូវតាមមើលកម្មវិធីដែលពួកគេលេងឱ្យស្របតាមអាយុដែលគេអនុញ្ញាត្តិ នឹងប្រើម៉ោងពេលកុំឱ្យលើសពី២ម៉ោង ក្នុងមួយថ្ងៃ នាថ្ងៃឈប់សម្រាក ។ ចំណែកឯ ២-ចាស់ៗវិញ ត្រូវពិនិត្យផ្ទៀងព័ត៌មានដែលទទួល តើត្រឹមត្រូវដែរ ឬទេ ហើយបើបញ្ជូនទៅមិត្តភក្រ្តិវិញ ក៏ត្រូវមានភាពជាក់លាក់ មិនបណ្ដើមយកតែត្រូវ ដើម្បីឱ្យមានគេជឿយើងវិញបានផង, ជាពិសេសជាមួយនឹងក្រុមដែល មិនមានគំនិតដូចគ្នា ក៏ត្រូវបន្តការជជែកគ្នាដោយផ្ទាល់រំងាប់ភាពប្រទូសរាយគ្នាមិនមែនតែដោយសារភាពរឹងមាំខ្លាំងពេកនោះទេ ។

# The Cambodia Politics: "The Heat hit shallow, the Cool hit deeper"

By: Pin Samkhon, dated 15 October 2020



In recent months, my articles always take side to support Kem Sokha, the president of the National Rescue Party in Cambodia to challenge Sam Raingsy, the acting president who is living in oversea…why? Do I betray my journalism profession?

I want to remain independent meaning that "I have no personal intention but wanting to affirm about my will." The profession does not define "I have to position at the center of two controversial contradictory opinions." (Generally they require to sideline). I stand for 1) those who are morally do the right things, do not lie, and do no harm to others or make someone loose or insecure to others, 2) those who has political process in accordance with viewpoints of freedom, democracy and whom I give a high evaluation and 3) those who is showing of willingness without afraid of backfire reactions. I have done it and gave energetic guidance " we should not be afraid to talk about the facts which can be ideas for repairing of incitement, faking or correction of mistakes which so far no one has seen it…but there is return of cursing, slandering from those who are protecting the bad guys and uncooked people."

**"The heat hit shallow?"**



The National Rescue Party has an acting president of the Sam Raingsy Party who is still making a fuss about "Hun Sen as a bad Prime Minister and destroy the nation" but he also recognizes that "he has credits for the Cambodian People Party". Hun Sen also acknowledged an important political credit from Sam Raignsy who has liquidated the power of his opponent from two third to 50%+1.

Sam Raignsy continues to shout that "Sam Raingsy and Kem Sokha is one" but in real actions he always split the supporters of the National Rescue Party in oversea, everywhere and everyday regardless of critics. Sam Raingsy has not mobilized the party workforces as said in his motto but instead he offers a new credit to Hun Sen, meaning that Sam Raingsy has completely divided his party as Hun Sen wishes for.

There are many actions which Sam Raingsy's clan has done "as creditor to the Cambodian People Party" as resulted in the 2013 election when he did not care about the millions of public opinion who came out to the streets and expressed their upset toward the results of ballot which the National Rescue Party supposedly to win but Sam Raingsy announced to the protesters to "disperse" in 2014…afterward seemed to imagine of "going to Phnom Penh to arrest Hun Sen" people believe him still!

In summary, the struggling voice in the opposition party of Sam Raingsy did not meet a result as he wishes for but Hun Sen is the one who proclaimed himself as "the winner" until now. The voice of people who stood up and fought from flesh to blood behind the guidance of Sam Raingsy and guessed him as "great" because of his retreat less or coward less speech but it turned out to be shallow, no "informed consent plan", there is no recognition from the national and international organization and the voice in vote becomes shorter gradually until he decided to cede to the National Rescue Party's movement…so only his over proud prevails like a "fish was killed because of his mouth."

**"The Cool hit deeper"**

There is another remaining head of the National Rescue Party who I hope "he will be able to change of hands from Hun Sen", he is Kem Sokha, because of his caution and cool political process of dissolved National Rescue Party. He has not answered to many questions and making a lot of wonder "why Kem sokha and Sam Raingsy is one when the politics of both people are completely different?" "Why don't they create a stand for a new party or maintain the National Rescue Party to stay in course?" a number of his closest members ceded to renew their political rights in accordance with the new Election Law. "Are those politicians deserting the party? The arrest of Rong Chhun, head of the Worker Union led to a question "What does Kem Sokha think about it?" Instead, he suddenly appeared at the funeral of Hun Sen's mother in-law and raised impression among the publics and the international communities "Has Kem Sokha changed his political direction?"



Kem Sokha replied cautiously that "the court does not permit him to do political activities!" He does not do politic exactly but he expressed he donated money his through the government to fight "Covid-19" for 5000 US dollars, a little later he donated US 5000 dollars through the same government to help victims of the flood.

These are the purely tasks of the government but Kem Sokha still has plenty resources and appear his face through the same open door and raised suspicion of "whether Kem Sokha's supporters remain a lot?" still have money for "traditional ceremony-Kathen at the provinces where a lot of people gathering, he did not prepare any propaganda but he only came out for the national traditional ceremonies. Meaning that Kem Sokha 'did not do politic" but he said "I just celebrated ceremonies or doing humanitarian contribution according to the government permission only."

The same act has different meanings and the good one is the government wrote a letter of appreciation/thank you for the first time when most of the time have only negative answers and people concern about it. With the first letter from Hun Sen what does it indicate to the people and to the international communities? Some opinions accused that "why did he donate the money through the government and not donate it by himself to the people?" But the letter Hun Sen makes everyone know aware that there is "approach" between the two controversial parties. This question does not have answer from Kem Sokha. Furthermore, Hun Sen is ready to censure can't find any evidence but people are hungry and waiting for "change hands of power" the hands of charity in human rights to help people in emergency and they begin to suspect "if this cool politician hit deeper?" no network, no structure, not feet and arms but it is growing a ready hope in the heart of voters that "the real nation rescuers in whatever shape they are in will reborn with Kem Sokha."

**Finally, who is the winner?**

Hun Sen's politic is still at risk because 80% people is still poor, no chance to rise. So, changing of leadership is still the same before. For heating of Khmer people like the instigation of Sam Raingsy to uprising "to arrest Hun Sen" when he himself doesn't have a real intention and will be seen by everyone that he is going to lose support, he can win nothing and also the most dangerous man. People are the nation lover should not have interest with "the shameful liar."

In contrary, as long as we have Khmer politicians who respect rights, freedom, people are the owner of their vote, cautious about their safety, protect the people, to keep a political stand with love then the people will return with belief on the party, they create "a people movement" to support that party with regret for their lives and properties when they know that one particular party listen to their concerns and provide prosperity to them. Kem Sokha up to now has been doing a better activities for the National Rescue Party, he knows people, never run away from friends, never run away from his responsibility even though the local authority has attempted to arrest him. That is cool to collect the voters and together we hold hands together for a success.

# ឌឹ ឃែមបូឌា ដេលី The Cambodia Daily

អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ឃែមបូឌា ដេលី


## EU ផ្តល់ជំនួយសង្គ្រោះបន្ទាន់ជាទឹកប្រាក់ ៤៧ មុឺនដុល្លារអាមេរិកដល់ពលរដ្ឋខ្មែរដែលកំពុងរងវិបត្តិដោយទឹកជំនន់

By ឌឹ ខេមបូឌា ដេលី

-October 31, 2020

មន្ត្រីជាន់ខ្ពស់សហគមន៍អឺរ៉ុបអះអាងថា សហភាពអឺរ៉ុបបានផ្តល់ជំនួយមនុស្សធម៌ក្នុងទំហំទឹកប្រាក់៤០ម៉ឺនអឺរ៉ូ ស្មើនឹង៤៧ម៉ឺនដុល្លារអាមេរិក ឬត្រូវជា១ពាន់៩០០លានរៀល នឹងត្រូវដោះស្រាយតម្រូវការបន្ទាន់ជាក់ស្តែង ដើម្បីជួយដល់ពលរដ្ឋកម្ពុជាដែលកំពុងរងគ្រោះយ៉ាងធ្ងន់ធ្ងរបណ្តាលមកពីជំនន់ទឹកភ្លៀង។




លោក Olivier Brount មន្ត្រីជាន់ខ្ពស់របស់សហគមន៍អឺរ៉ុបទទួលបន្ទុកខាងមនុស្សធម៌ប្រចាំតំបន់មេគង្គបញ្ជាក់ថា ជំនួយមនុស្សធម៌នេះបង្ហាញពីសាមគ្គីភាពរបស់សហគមន៍អឺរ៉ុបជាមួយប្រជាជនកម្ពុជាដែលកំពុងរងគ្រោះដោយទឹកជំនន់ចាប់ពីដើម ខែតុលា មក ដែលបានបណ្តាលឱ្យខូចខាតផ្ទះសម្បែងជាច្រើនខ្នង និងបានបាត់បង់អាយុជីវិតមនុស្សជាច្រើននាក់។

លោកថា មូលនិធិនេះ គឺជាគម្រោងដ៏ធំមួយសម្រាប់ឆ្លើយតបភ្លាមៗរបស់សហគមន៍អឺរ៉ុប ដែលនឹងជួយជ្រោមជ្រែងដល់ដៃគូរមនុស្សធម៌ជាច្រើនទៀត ក្នុងការសង្គ្រោះជីវិតប្រជាជនដែលងាយរងគ្រោះ និងធានាឱ្យបាននូវភាពគ្រប់គ្រាន់របស់ពួកគេក្នុងពេលដ៏លំបាកនេះ។

មន្ត្រីជាន់ខ្ពស់រូបនេះ អះអាងថា ថវិកាមនុស្សធម៌នេះនឹងផ្តល់ជូនដល់ពលរដ្ឋរងគ្រោះទាំងនោះដោយផ្ទាល់ផងដែរ ដើម្បីផ្គត់ផ្គង់លើម្ហូបអាហារ និងសេចក្តីត្រូវការជាក់ស្តែងរបស់ពួកគេ ក្នុងនោះក៏បានផ្តោតទៅលើពលរដ្ឋងាយរងគ្រោះបំផុត ក្រុមមនុស្សដែលបាត់បង់ឱកាសរួមបញ្ចូលទាំងស្ត្រីដែលជាមេគ្រួសារ និងពលរដ្ឋដែលបាត់បង់លទ្ធភាពទៀតផង។

ការអះអាងនេះធ្វើឡើងក្នុងសេចក្តីប្រកាសព័ត៌មានមួយរបស់សហគមន៍ អឺរ៉ុបចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ កន្លងទៅ ដែលលើកឡើងថាសហគមន៍អឺរ៉ុបផ្តល់ទឹកប្រាក់៤៧ម៉ឺនដុល្លារអាមេរិកដើម្បីជួយពលរដ្ឋរងគ្រោះដោយទឹកជំនន់នៅកម្ពុជា។

ក្នុងសេចក្តីប្រកាសព័ត៌មានដដែលនេះ បញ្ជាក់ថា មូលនិធិនេះនឹងឧបត្ថម្ភដល់អង្គការមិនមែនរដ្ឋាភិបាលធំៗចំនួន២ គឺអង្គការសង្គ្រោះកុមារ (Save the Children) និងអង្គការទស្សនៈពិភពលោក (World Vision) ដើម្បីចែកចាយជំនួយដ៏ចំបាច់ និងបន្ទាន់ទាំងនេះ រួមមានការចែកចាយទឹកស្អាតឧបករណ៍អនាម័យវិធីអនុវត្តអនាម័យឱ្យបានល្អ និងជំនួយសង្គ្រោះបន្ទាន់ផ្សេងៗទៀត។

ចាប់តាំងពីដើមខែតុលា ឆ្នាំ២០២០នេះ ជំនន់ទឹកភ្លៀងបន្តឡើងឥតឈប់ ដែលបានប៉ះពាល់ជីវភាពប្រជាពលរដ្ឋសរុបជាង៦០ម៉ឺននាក់ និងធ្វើឱ្យខូចខាតលំនៅឋានជាង១៣ម៉ឺនខ្នង ព្រមទាំងពលរដ្ឋរងគ្រោះដែលបានជម្លៀសចេញមានប្រមាណជិត៥ម៉ឺននាក់ ជាងនេះទៀត ប្រទេសកសិកម្មដ៏ធំមួយនេះបានរងការខូចខាតហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាច្រើន រួមមានមជ្ឈមណ្ឌលសុខភាព អាគារសិក្សា ស្ពាន និងផ្លូវថ្នល់ ជាដើមយ៉ាងធ្ងន់ធ្ងរ។

អ្នកវិភាគនយោបាយសង្គម លោក គឹម សុខ បានប្រាប់ The Cambodia Daily នៅថ្ងៃនេះថា ជំនួយមនុស្សធម៌របស់សហភាពអឺរ៉ុប ផ្តោតការយកចិត្តទុកដាក់ជួយពលរដ្ឋរងគ្រោះជាក់ស្តែងយ៉ាងពិតប្រាកដ។ សហគមអន្តរជាតិនេះ តែងផ្តល់ជំនួយបែបនេះ ទៅដល់ពលរដ្ឋគ្រប់ជាតិសាសន៍ដែលជួបគ្រោះទុរភិក្សនៅជុំវិញពិភពលោក សូម្បីតែប្រទេសផ្តាច់ការដូចកូរ៉េខាងជើងក៏ធ្លាប់ទទួលបានជំនួយរបស់ពួកគេដែរ ។

លោកបញ្ជាក់ថា ជំនួយនេះជាការបង្ហាញឱ្យឃើញថា សហភាពអឺរ៉ុបក្តីអង្គការសហប្រជាជាតិក្តី គឺតែងនៅជាមួយពលរដ្ឋខ្មែរ និងគាំទ្រពលរដ្ឋខ្មែរគ្រប់កាលៈទេសៈ ទោះក្នុងស្ថានភាពណាក៏ដោយ ជាពិសេសគាំទ្រឱ្យមានការប្រើសិទ្ធិស្របតាមរដ្ឋធម្មនុញ្ញរបស់ប្រជាពលរដ្ឋ ដែលប្រាថ្នាចង់បានប្រជាធិបតេយ្យ ។

មូលធិនិរបស់សហគមន៍ អឺរ៉ុបត្រូវបានរៀបចំឡើងដោយកិច្ចសហប្រតិបត្តិការការពារជនស៊ីវិល និងជំនួយមនុស្សធម៌របស់គណៈកម្មាធិការអឺរ៉ុប (ECHO) ជាផ្នែកមួយនៃឆ្លើយតបបន្ទាន់យ៉ាងស្រួចស្រាវ របស់សហភាពអឺរ៉ុប ដែលមានគោលបំណងឆ្លើយតបឱ្យបានទាន់ពេលចំពោះពលរដ្ឋដែលងាយរងគ្រោះ។

## ទណ្ឌិតជិត៧០០នាក់ ត្រូវបានស្នើសុំលើកលែង និងបន្ធូរបន្ថយទោស នាឱកាសបុណ្យអុំទូក

By ឌឹ ខេមបូឌា ដេលី

-October 31, 2020

មន្ត្រីជាន់ខ្ពស់ក្រសួងយុត្តិធម៌បានឱ្យដឹងថា ទណ្ឌិតជិត៧០០នាក់ (៦៩៥) ក្នុងនោះមានស្រី ៦៥នាក់ ត្រូវបានដាក់ទៅក្នុងបញ្ជីស្នើសុំលើកលែងទោស និងបន្ធូរបន្ថយទោស នៅក្នុងឱកាសពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុកឆ្នាំ២០២០នេះ។



ទំព័រហ្វេសប៊ុករបស់អ្នកនាំពាក្យក្រសួងយុត្តិធម៌ លោក គឹម សន្តិភាព កាលពីថ្ងៃម្សិលមិញបញ្ជាក់ថា ទណ្ឌិតជាង១ពាន់នាក់ មកពីតាមបណ្តាពន្ធនាគាររាជធានី-ខេត្តចំនួន២៤និងមណ្ឌលអប់រំកែប្រែចំនួន៤ បានដាក់ពាក្យសុំស្នើបន្ធូរបន្ថយ និងលើកលែងទោស នាឱកាសពិធីបុណ្យអុំទូក។ ប៉ុន្តែលោកថា ជាលទ្ធផលនៃការពិនិត្យ និងវាយតម្លៃមានតែទណ្ឌិត ៦៩៥ នាក់ប៉ុណ្ណោះ ត្រូវបានសម្រេចបញ្ចូលទៅក្នុងបញ្ជីសម្រាប់ស្នើសុំបន្ធូរបន្ថយ និងលើកលែងទោស។

ប្រភពដដែលបញ្ជាក់ថា ទណ្ឌិតដែលត្រូវបានជ្រើសរើសលើកលែង និងបន្ធូរបន្ថយទោសទាំងនោះ ត្រូវបានពិនិត្យ និងវាយតម្លៃពីសំណាក់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងប្រធានគណៈកម្មការថ្នាក់ជាតិទៀតផង។

តាមនីតិវិធីក្រោយការសម្រេចជ្រើសរើសរួចបញ្ជីឈ្មោះទណ្ឌិតទាំងនោះ ត្រូវបានស្នើទៅលោកនាយករដ្ឋមន្ត្រីហ៊ុនសែនដើម្បីទូលថ្វាយព្រះមហាក្សត្រដើម្បីព្រះរាជទានការអនុគ្រោះទោសដល់ពួកគេ។

អ្នកនាំពាក្យក្រសួងយុត្តិធម៌ដដែលឱ្យដឹងទៀតថា ទណ្ឌិតទាំង ៦៩៥នាក់នោះ នឹងត្រូវដាក់ស្នើសុំបន្ថយទោសមួយជីវិតមកនៅត្រឹមទោស២០ឆ្នាំចំនួន៥នាក់, ស្នើសុំលើកលែងទោសចំនួន១៩នាក់ ក្នុងនោះអ្នកមានជំងឺរ៉ាំរ៉ៃ និងចាស់ជរា។ ចំណែកទណ្ឌិត ដែលស្នើសុំបន្ធូរបន្ថយទោស១២ខែមាន៩២នាក់ហើយស្នើសុំបន្ធូរបន្ថយទោស៩ខែមាន៩៥នាក់ និងស្នើសុំបន្ធូរបន្ថយទោស៦ខែ មានចំនួន៤៨៤នាក់។ ប៉ុន្តែលោកមិនបានបង្ហាញបញ្ជីឈ្មោះទណ្ឌិតដែលត្រូវស្នើសុំលើកលែង និងបន្ធូរបន្ថយទោសនោះឡើយ។

កន្លងមកក្រុមសង្គមស៊ីវិល តែងស្នើឱ្យរដ្ឋាភិបាលធ្វើការងារនេះ ដោយតម្លាភាព គ្មានអំពើពុករលួយ និងមិនត្រូវរើសអើងនយោបាយនោះឡើយ។ ការស្នើនេះ ដោយសារកន្លងមកការស្នើសុំលើកលែង និងបន្ធូរបន្ថយទោសនេះ ធ្វើឡើងដោយគ្មានតម្លាភាព និងមានពាក់ព័ន្ធអំពើពុករលួយផងដែរ។

ជាក់ស្តែង អតីតមន្ត្រីគណបក្សសង្គ្រោះជាតិ និងសកម្មជនសិទ្ធិមនុស្សតែងគ្មានឈ្មោះ ក្នុងបញ្ជីស្នើសុំលើកលែងទោស និងបន្ធូរបន្ថយទោសនោះឡើយ បើទោះបីជាពួកគេគ្រប់លក្ខខណ្ឌដើម្បីដាក់ស្នើសុំយ៉ាងណាក្តី។

ការលើកលែង និងបន្ធូរបន្ថយទោសដល់ទណ្ឌិតនៅកម្ពុជា ត្រូវបានធ្វើឡើង៣លើកក្នុងមួយឆ្នាំ រួមមានក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ ពិធីបុណ្យពិសាខបូជា និងពិធីបុណ្យអុំទូក។

# ឌឹ ឃែមបូឌា ដេលី The Cambodia Daily

## អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ឃែមបូឌា ដេលី

### លោក កឹម សុខា បញ្ជាក់ថា ភាពបរិសុទ្ធរបស់មនុស្សល្អមិនអាចនរណាម្នាក់លុបបំបាត់បានឡើយ ទោះត្រូវគេមួលបង្កាច់លាបពណ៌យ៉ាងណាក៏ដោយ

By ឌឹ ខេមបូឌា ដេលី

- October 31, 2020

មេបក្សប្រឆាំងដែលកំពុងរងការរឹតត្បិតសេរីភាពបានអះអាងថា មនុស្សបរិសុទ្ធដែលមានគុណតម្លៃពិត ទោះបីទទួលរងការចោទប្រកាន់មួលបង្កាច់ ការជេរប្រមាថ លាបពណ៌ មានឬមិនមានតួនាទីឋានៈបុណ្យស័ក្តិធ្លាក់ដល់ទីណាក៏ដោយ ក៏បណ្ឌិតរូបនោះនៅតែស្វះស្វែងរកទទួលស្គាល់ និង



ផ្តល់តម្លៃចំពោះបុគ្គលដែលតម្កល់នូវគុណធម៌ជាធំនោះដែរ។

លោក កឹម សុខា ប្រធានអតីតគណបក្សសង្គ្រោះជាតិបានបង្ហោះសារលើគណនីយ ហ្វេសប៊ុក ផ្លូវការរបស់លោកថា ប្រទេសជាមិត្តដែលប្រកាន់យកនូវគោលការណ៍ប្រជាធិបតេយ្យលើកស្ទួយគុណតម្លៃសិទ្ធិមនុស្ស នៅតែគោរព និងផ្តល់តម្លៃដល់រូបលោកក្នុងនោះមានទូតតំណាងប្រទេសខ្លះ ដែលមានស្ថានទូតនៅប្រទេសថៃ ទោះបីមិនអាចធ្វើដំណើរមកជួបលោកផ្ទាល់ ក៏តែងតែផ្ញើរសារមកសួរសុខទុក្ខ និងចង់ដឹងពីស្ថានភាពសិទ្ធិសេរីភាព សុវត្ថិភាពរបស់លោក ហើយបន្តតាមដានឃ្លាំមើលស្ថានភាពរបស់លោកជាប្រចាំផងដែរ។

លោកថា ជាងនេះទៀតក៏មានមន្ត្រីទូតដែលជាតំណាងប្រទេសផ្សេងទៀត មកជួបលោកដល់គេហដ្ឋាននិងអញ្ជើញលោកទៅស្ថានទូតរបស់ពួកគេ ដើម្បីសួរសុខទុក្ខទទួលទានអាហារសម្តែងពីកង្វល់ ចំពោះស្ថានភាពសិទ្ធិសេរីភាពសុវត្ថិភាពរបស់លោក និងបញ្ជូនវេជ្ជបណ្ឌិតមកជួយពិនិត្យព្យាបាល ហើយតាមដានសុខភាពលោកជាញឹកញាប់។ លោកអះអាងថា មាសទឹកដប់ ទោះបីគេទម្លាក់ក្នុងភក់ជ្រាំ ក៏នៅតែជាមាសទឹកដប់ និងនៅតែមានតម្លៃដដែល។

មេបក្សប្រឆាំងរូបនេះបានថ្លែងអំណរគុណដល់ជនរួមជាតិខ្មែរទាំងក្នុង និងក្រៅប្រទេស ដែលនៅតែគាំទ្រនូវជំហរអហិង្សា មិនយកខ្មែរណាជាសត្រូវការតស៊ូអត់ធ្មត់របស់លោក និងគោរពស្រឡាញ់រាប់អាន នឹករលឹក ដោយបានមកសួរសុខទុក្ខរូបលោកដល់គេហដ្ឋានស្កាត់ជួបនៅទីសាធារណៈ និងតាមរយៈការផ្ញើរសារពីចម្ងាយផងដែរ។

ម្យ៉ាងវិញ ពួកគេបានធ្វើជំនួយមនុស្សធម៌តាមរយៈរូបលោក ជួយដល់ពលរដ្ឋខ្មែរដែលរងគ្រោះដោយទឹកជំនន់ ជាមួយនឹងអាជ្ញាធររដ្ឋាភិបាល និងធ្វើដោយផ្ទាល់ទោះបីលោកស្ថិតនៅក្នុងស្ថានភាពណាក៏ដោយ។

លោក មុត ចន្ថា មន្ត្រីជាន់ខ្ពស់អតីតបក្សសង្គ្រោះជាតិបានអះអាងថា មនុស្សជាតិគឺប្រៀបបាននឹងមហាសមុទ្រ ទោះបីទឹកសមុទ្រល្អក់២-៣ដំណក់ក៏មិនអាចធ្វើឱ្យមហាសមុទ្រទាំងមូលក្លាយជាល្អក់បានដែរ។

លោក កឹម សុខា អតីតប្រធានគណបក្សសង្គ្រោះជាតិ ត្រូវបានតុលាការចោទប្រកាន់ពីបទឃុបឃិតជាមួយបរទេសដើម្បីផ្តួលរំលំរដ្ឋាភិបាលកម្ពុជាហើយត្រូវអាជ្ញាធរកម្ពុជាចាប់ឃុំខ្លួន កាលពីខែកញ្ញា ឆ្នាំ២០១៧កន្លងទៅ។ ក្រោយមកលោកត្រូវបានផ្ទេរការឃុំខ្លួនពីពន្ធនាគារត្រពាំងផ្លុងក្នុងខេត្តត្បូងឃ្មុំ មកឃុំឃាំងក្នុងផ្ទះរបស់លោកវិញនៅក្រោមហេតុផលសុខភាពមិនប្រក្រតី។

ប៉ុន្តែនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៩ តុលាការក្រុងភ្នំពេញបានចេញដីកាដោះលែងរូបលោកឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ប៉ុន្តែស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការដដែល។ នៅក្រោមលក្ខខណ្ឌថ្មីនេះលោកកឹមសុខា មានសេរីភាពដើរហើរនៅគ្រប់ទីកន្លែងទូទាំងប្រទេសកម្ពុជា ប៉ុន្តែហាមមិនឱ្យចេញទៅក្រៅប្រទេស ឬធ្វើសកម្មភាពនយោបាយឡើយ។

មន្ត្រីជាន់ខ្ពស់អតីតបក្សប្រឆាំង លោក មាជ សុវណ្ណារ៉ា អះអាងថាមានតែធ្វើការតស៊ូមតិដោយអហិង្សាតាមប្រព័ន្ធតុលាការ និងតាមរយៈអង្គទូតនានាប៉ុណ្ណោះ ទើបអាចដោះស្រាយវិបត្តិនយោបាយនៅកម្ពុជាបាន ទោះត្រូវមានការចោទប្រកាន់ពីមជ្ឈដ្ឋានខ្លះក៏ដោយ ត្បិតការដោះស្រាយដោយប្រើវិធីផ្តួលរំលំ គឺជាការបង្កើតឱ្យមានការបែកបាក់ជាតិកាន់តែធ្ងន់ធ្ងរទៅវិញ។

ក្រុមអ្នកឃ្លាំមើលអំពាវនាវឱ្យរដ្ឋាភិបាលកម្ពុជាលើកលែងការចោទ លោក កឹម សុខា ត្បិតការចោទប្រកាន់នេះគឺជារឿងនយោបាយសុទ្ធសាធ មិនមែនជាកំហុសផ្លូវច្បាប់ដូចការលើកឡើងនោះឡើយ។

យ៉ាងណាក៏ដោយ សំណុំរឿងរបស់ប្រធានគណបក្សសង្គ្រោះជាតិលោក កឹម សុខា កំពុងស្ថិតនៅក្នុងដំណើរការនីតិវិធីកាត់សេចក្តីរបស់តុលាការក្រុងភ្នំពេញនៅឡើយក្នុងពេលបច្ចុប្បន្ននេះ។

### លោក ហ៊ុន សែន ប្រាប់ឱ្យអាជ្ញាធរទាំងអស់រក្សាសណ្តាប់ធ្នាប់ក្នុងឱកាសបុណ្យអុំទូក ទោះបីជាពិធីនេះខកខានមិនបានប្រារព្ធក្តី

By ឌឹ ខេមបូឌា ដេលី

- October 31, 2020

លោក ហ៊ុន សែន បានអំពាវនាវដល់អាជ្ញាធរ និងសមត្ថកិច្ចទាំងអស់ត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ឱ្យបានល្អ ដើម្បីឱ្យពលរដ្ឋ និងទេសចរបរទេសមានឱកាសសប្បាយរីករាយក្នុងថ្ងៃឈប់សម្រាកក្នុងពិធីបុណ្យអុំទូកនៅឆ្នាំនេះ បើទោះបីមិនមានពិធីបុណ្យអុំទូកនៅភ្នំពេញក្តី។

ទំព័រហ្វេសប៊ុករបស់លោក ហ៊ុន សែន នៅថ្ងៃ៣០ខែតុលាបានបញ្ជាក់ថាឪថ្ងៃនេះជាថ្ងៃដំបូងនៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីបសំពះ



ព្រះខែ និងអកអំបុក សម្រាប់ឆ្នាំ២០២០។ ប៉ុន្តែថ្វីត្បិតមិនមានពិធីប្រណាំងទូកនៅទីក្រុងភ្នំពេញក៏ដោយក៏ពលរដ្ឋអាចកម្សាន្តសប្បាយរីករាយនៅតាមបណ្តាខេត្តនានា ទៅតាមទំនៀមទម្លាប់របស់ខ្មែរដែរ។

លោក ហ៊ុន សែន ក៏បានអំពាវនាវឱ្យពលរដ្ឋត្រូវមានការប្រុងប្រយ័ត្នជាប់ជានិច្ច និងទប់ស្កាត់ការចម្លងជំងឺកូវីដ១៩ ដោយត្រូវអនុវត្តឱ្យបានជាប់ជាប្រចាំនូវការណែនាំរបស់ក្រសួងសុខាភិបាល។

ប្រភពដដែលក៏បានបញ្ជាទៅអាជ្ញាធរ និងសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ឱ្យបានល្អក្នុងឱកាសឈប់សម្រាកនេះផងដែរ។

រដ្ឋាភិបាលបានប្រកាសផ្អាកការរៀបចំពិធីបុណ្យអុំទូកនៅឆ្នាំ២០២០នេះ ក្រោមហេតុផលដើម្បីទប់ស្កាត់ ការរីករាលដាលជំងឺកូវីដ១៩ ស្របពេលដែលកម្ពុជាកំពុងរងគ្រោះធ្ងន់ធ្ងរដោយទឹកជំនន់ផងដែរ។ ត្បិតតែមិនមានការរៀបចំពិធីបុណ្យអុំទូកនៅភ្នំពេញក្តី ប៉ុន្តែមន្ត្រីរាជការ បុគ្គលិកឯកជនកម្មករជាដើមត្រូវបានអនុញ្ញាតឱ្យឈប់សម្រាករយៈពេល៤ថ្ងៃ ចាប់ពីថ្ងៃទី ៣០ខែតុលា ដល់ថ្ងៃទី២ខែវិច្ឆិកា។

កាលពីបណ្តាឆ្នាំមុនៗ ព្រះរាជពិធីបុណ្យអុំទូកត្រូវបានរដ្ឋាភិបាលផ្អាកការរៀបចំជាច្រើនលើកក្រោមហេតុផលផ្សេងៗ ដូចជាព្រះមហាក្សត្រសម្តេចព្រះនរោត្តម សីហនុ យាងសោយទីវង្គត់ បញ្ហាទឹកជំនន់ និងទឹកទន្លេមេគង្គរាក់ពេកជាដើម។

## តមកពីទំព័រទី ០១ កម្ពុជាប្រតិកម្មនឹងសំណើរដកកម្ពុជា...

អំពីការណ៍ដែលរដ្ឋសមាជិកទាំងពីរបណ្ដែតបណ្ដោយឱ្យ "មហាអំណាចខាងក្រៅមួយ" ដែលលោកទំនងសំដៅទៅលើប្រទេសចិនឱ្យប្រើប្រាស់នូវអំណាចយន្តការតំបន់ដែលខ្លួនមានដូចយ៉ាងយន្តការអាស៊ានជាដើម ដើម្បីសម្រេចមហិច្ឆិតារបស់ខ្លួន។ មកដល់ចំណុចនេះលោក Bilahari Kausikan បានឈានដល់ការលើកសំណើថា "យើងប្រហែលជាត្រូវកាត់បន្ទរចេញប្រទេសទាំងពីរ ដើម្បីសង្គ្រោះប្រទេសទាំងប្រាំបីផ្សេងទៀតដែលនៅសេសសល់"។ មន្ត្រីជាន់ខ្ពស់កម្ពុជាលោក កៅ គឹមហួន និយាយថា គេចង់ដឹងអំពីគោលបំណងពិតប្រាកដនៃការលើកឡើងបែបនេះ។ លោកបន្តថា ការចោទប្រកាន់ថាសមាជិកអាស៊ានណាមួយជា "កូនជឹង" នៃមហាអំណោចជាគំនិត "ចាស់គំរឹលហើយគួរត្រូវបានទម្លាក់ចោលពីការគិត និងវចនានុក្រមរបស់អាស៊ាន"។ លោក កៅ គឹមហួន ឆ្លៀតបន្ថែមថា "គ្មានអ្នកណាមួយ ឬប្រទេសណាមួយចង់ធ្វើជាកូនជឹងរបស់ប្រទេសណាមួយឡើយ"។ នៅថ្ងៃសុក្រនេះ លោក Bilahari Kausikan បានឆ្លើយតបនឹងសំណួររបស់ VOA ទាក់ទងនឹងការអត្ថាធិប្បាយរបស់លោក កៅ គឹមហួនថា: "ខ្ញុំគិតថាគាត់មិនបានអានអ្វីដែលខ្ញុំបានសរសេរនោះទេ ហើយបើទោះជាគាត់បានអាន ក៏ខ្ញុំគិតថា គាត់មិនយល់អ្វីដែលខ្ញុំសរសេរនោះដែរ"។ លោកបានសរសេរបន្ថែមថា: "ខ្ញុំគិតថា រឿងគាត់យល់ ឬ


លោក កៅ គឹមហួន

មិនយល់មិនថ្វីនោះទេព្រោះថាក្នុងប្រទេសកម្ពុជានាបច្ចុប្បន្ននេះ គាត់ត្រូវតែនិយាយដូច្នេះ មិនសំខាន់ទាល់តែសោះត្រង់ថាតើគាត់យល់ឬមិនយល់នោះទេ"។ ប្រទេសចិនគឺជាម្ចាស់បំណុលធំបំផុត របស់ប្រទេសកម្ពុជា និងលាវ។ VOA មិនទាន់អាចទាក់ទងលោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា ដើម្បីសុំការឆ្លើយតបទៅនឹងការលើកឡើងរបស់អតីតមន្ត្រីការទូតសិង្ហបុរីបាននៅឡើយទេ។ តែលោកបានប្រាប់បណ្ដាញសារព័ត៌មានក្នុងស្រុកថា ការលើកឡើងរបស់លោក Kausikan មិនប៉ះពាល់អ្វីដល់ទំនាក់ទំនងរដ្ឋនិងរដ្ឋរវាងកម្ពុជា និងសិង្ហបុរីនោះទេ ។ ក្រសួងការបរទេសសិង្ហបុរីទៀតសោតក៏បានសម្ដែងភាពស្ងៀមស្ងាត់ មិនមានយោបល់អ្វីទាំងអស់ចំពោះការថ្លែងដំចម្រូងចម្រាសរបស់អតីតអ្នកការទូតជាន់ខ្ពស់មួយរូបរបស់ខ្លួន។ ការថ្លែងរបស់លោក កៅ គឹមហួន ជាប្រតិកម្មតបពីមន្ត្រីរដ្ឋាភិបាលកម្ពុជាថ្នាក់ខ្ពស់បំផុតមកទល់ពេលនេះ ទៅនឹងការលើកឡើងរបស់លោក Bilahari Kausikan ហើយមានលក្ខណៈថ្នមសម្ដីជាងប្រតិកម្មនៃលិខិតចំហអនាមិកមួយរបស់ក្រុមអតីតអ្នកការទូត និងអ្នកការទូតបច្ចុប្បន្ននៃក្រសួងការបរទេសកម្ពុជា និងត្រូវបានផ្សាយដោយប្រព័ន្ធឃោសនារដ្ឋ។ "អ្នកចម្បាំងចចកសិង្ហបុរីម្នាក់កំពុងបំផ្លាញសាមគ្គីភាព និងមជ្ឈភាពអាស៊ាន"។ នេះជាខ្លឹមសារនៃលិខិតដែលត្រូវបានចែកចាយកាលពីថ្ងៃច័ន្ទ និងដែលបានបន្ថែមថា កុងសង់ស៊ុលដែលអវត្តមានលាវ និងកម្ពុជា ជា "កុងសង់ស៊ីសទន់ជ្រាយ"។

នេះជាការលើកឡើងដំបូងរបស់មន្ត្រីជាន់ខ្ពស់កម្ពុជា លោក កៅ គឹមហួន ដែលជាមន្ត្រីជំនិតផ្ដល់ប្រឹក្សាដល់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន លើកិច្ចការបរទេសនិងអាស៊ាន។ លោក កៅ គឹមហួន ក៏ជាបេក្ខភាពកូតាកម្ពុជា ដែលនាយករដ្ឋមន្ត្រីឧទ្ទេសនាមឱ្យទៅកាន់តំណែង ជាអគ្គលេខាធិការអាស៊ានពីឆ្នាំ ២០២៣ ដល់ឆ្នាំ ២០២៧។ បើគ្មានអ្វីប្រែប្រួល ការចូលទៅកាន់តំណែងជាអគ្គលេខាធិការអាស៊ានរបស់លោក កៅ គឹមហួន នឹងកើតឡើងក្រោយពីការធ្វើប្រធានអាស៊ានរបស់កម្ពុជា នៅឆ្នាំ ២០២២។ លោកទំនងជានឹងក្លាយជាជនជាតិកម្ពុជាដំបូង ដែលកាន់តំណែងប្រមុខរដ្ឋបាលនៃអង្គការថ្នាក់តំបន់នេះ ចាប់តាំងពីកម្ពុជាចូលជាសមាជិកកូនពៅនៃសមាគមអាស៊ាននៅឆ្នាំ១៩៩៩មក។



ទង់ជាតិប្រទេសអាស៊ានទាំង១០

ដកស្រង់ពី VOA




## តមកពីទំព័រទី ០៥ នាយឧត្តមសេនីយ៍បាតដៃកង្វក់១២រូប

តាំងពីពេលនោះមកលោក ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជាចាប់ផ្ដើមយុទ្ធនាការរំលោភសិទ្ធិមនុស្សដោយដៅមុខសញ្ញាទៅរកគណបក្សសង្គ្រោះជាតិ និងប្រព័ន្ធផ្សព្វផ្សាយព្រមទាំងសង្គមស៊ីវិលដោយអះអាងថា នេះជាវិធានការចាំបាច់ក្នុងការបង្ការកុំឱ្យមាន "បដិវត្តពណ៌" ដែលថា បើមិនទប់ស្កាត់ទេ បដិវត្តពណ៌នឹងអាចកើតឡើងពាក់ព័ន្ធនឹងការបោះឆ្នោតនៅឆ្នាំ២០១៨ រាប់ទាំងការតវ៉ាប្រឆាំងនឹងការលួចបន្លំសន្លឹកឆ្នោតផង។

របាយការណ៍នេះចាប់ផ្ដើមឡើងដោយមានប្រវត្តិលម្អិតអំពីកម្លាំងសន្តិសុខបីផ្នែកសំខាន់ ដែលមាននៅរហូតមកដល់សព្វថ្ងៃនេះ គឺកងទ័ពកងរាជអាវុធហត្ថ និងនគរបាល។ ការវិវឌ្ឍនៃខ្សែបញ្ជារបស់ពួកគេសូមមើលក្នុងឧបសម្ព័ន្ធ ទី ២, ៣, និង ទី៤។ ឧបសម្ព័ន្ធនេះបន្តដោយប្រវត្តិបុគ្គលទាំង១២ រូប។ របាយការណ៍នេះ គឺបញ្ចប់ដោយការផ្ដល់អនុសាសន៍សម្រាប់ធ្វើកំណែទម្រង់ផ្នែកកងកម្លាំងសន្តិសុខ ដែលបានលើកឡើងជាមួយរាជរដ្ឋាភិបាលកម្ពុជា, អង្គការសហប្រជាជាតិ, ម្ចាស់ជំនួយ និងរដ្ឋាភិបាលផ្សេងៗទៀត។ អនុសាសន៍ទាំងនេះ ត្រូវបានធ្វើឡើងតាមការបង្ហាញពីភាពបរាជ័យនៃកិច្ចប្រឹងប្រែងរបស់សហគមន៍អន្តរជាតិនៅក្នុងវិស័យនេះ។ ប៉ុន្តែដោយទទួលស្គាល់ថា ការកែទម្រង់ផ្នែកសន្តិសុខ គឺមានសារសំខាន់បំផុត សម្រាប់ការលើកស្ទួយ និងការពារសិទ្ធិមនុស្សនៅប្រទេសកម្ពុជា។ ប្រសិនបើមិនធ្វើឱ្យកងកម្លាំងសន្តិសុខមានវិជ្ជាជីវៈ ហើយជនរំលោភបំពានសំខាន់ៗមិនបានទទួលខុសត្រូវសមស្របទេនោះ លទ្ធភាពកែទម្រង់លទ្ធិប្រជាធិបតេយ្យមានតិចតួច ឬការកែទម្រង់រចនាសម្ព័ន្ធណាមួយនៅប្រទេសកម្ពុជាពិតជាមិនអាចទៅរួចទេ។

សូម មើលជំពូក ១៤ សម្រាប់អនុសាសន៍ពេញលេញទាំងស្រុង។

# ទឹកជំនន់នៅកម្ពុជាជាឱកាសជួបជុំគ្នា

ដោយ ពិន សំខុន

“ទឹកធំ”នាខែតុលាឆ្នាំ២០២០ ជាទឹកជំនន់ដ៏ធំបំផុតមួយ មិនត្រឹមតែធ្វើឱ្យពលរដ្ឋខ្មែរខូចខាតទ្រព្យសម្បត្តិដែលមានបន្តិចបន្តួចតែប៉ុណ្ណោះទេ ថែមទាំងមានបញ្ហាជម្រក ខ្វះស្បៀងអាហារ ខ្វះថ្នាំសង្កូវ នឹងជន្លៀសគ្រួសារទៀតផង។បញ្ហាដ៏ច្រើនកើតក្នុងរយៈពេលតែមួយប៉ព្រិចភ្នែក បានក្លាយជាសោកនាថកម្ម ដ៏ខ្លោចផ្សារសម្រាប់ពេល ដែលនឹងអូសបន្លាយដ៏វែង សម្រាប់អ្នករងគ្រោះទាំងនោះ។ បុព្វហេតុ គឺគេបានទម្លាក់កំហុសទៅលើទឹកភ្លៀងបានបង្អុរយ៉ាងច្រើនហួសហេតុ តែមួយមុខ រីឯទឹកទន្លេមេគង្គមិនបានពេញពាបហូរចេញមកទេ។

ទឹកលិចខ្លាំងជាងគេ គឺនៅបន្ទាយមានជ័យលិចរហូតដល់អូរជ្រៅដែលបណ្តាលឱ្យមនុស្ស១០នាក់ស្លាប់នឹងត្រូវជន្លៀស១៥០នាក់ទៀត,... ប៉ុន្តែរដ្ឋាភិបាលប្រកាសថា ទឹកជំនន់បានប៉ះពាល់ដល់ខេត្តបាត់ដំបង-ពោធិសាត់-កំពង់ស្ពឺ និងកំពង់ឆ្នាំង ដែលមានមនុស្ស១៤ពាន់នាក់ត្រូវជន្លៀសចេញទៅរកកន្លែងសុវត្ថិភាព ហើយដំណាំលើដីស្រែ៤ម៉ឺនហិកតា ត្រូវខូចខាត។ បុព្វហេតុនៃភ្លៀងដ៏ធំចាប់តាំងពីដើមខែតុលាមក គឺខ្យល់ព្យុះត្រូពីកាល់ “លីនហ្វា”បានបក់បោកសំដៅមក“ក្វាងទ្រី”ប្រទេសវៀតណាមកណ្តាល ក៏ជះឥទ្ធិពលជាភ្លៀងរហូតដល់មកកម្ពុជានឹងប្រទេសឡាវផងដែរ។ នៅកម្ពុជាដដែលមានសេចក្តីរាយការថា មានទឹកឡើងខ្លាំងដែរ នៅខែត្តកណ្តាល-ស្វាយរៀង-ប៉ៃលិន នឹងស្ទឹងត្រែង រួមទាំងសៀមរាបផងដែរ ដែលមានភ្លៀង ធ្លាក់២៤ម៉ោង ទឹកឡើងកំពស់១០៦.៥មម ។

ទំហំនៃគ្រោះទឹកជំនន់មានទូទាំងប្រទេសទៅហើយ រដ្ឋាភិបាលបានបញ្ចេញកងទ័ព មកជាជំនួយបន្ទាន់ ក្នុងការជន្លៀសប្រជាពលរដ្ឋ ដែលជាសកម្មភាពធំរបស់កងទ័ពខ្មែរដំបូង១ ដើម្បីសង្គ្រោះប្រជាជនខ្លួនឯង។

ជាពិសេសទៅទៀតនោះ ប្រធានគណបក្សប្រឆាំងលោក កឹម សុខា អតីតសង្គ្រោះជាតិបានត្រូវគេឃើញចេញមកចែកអំណោយសង្គ្រោះដល់គ្រួសាររងគ្រោះ ដែលលើកនេះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ពុំទាន់មានវិធានការ ឬទិទៀនសកម្មភាពដែលលោកធ្លាប់ច្រឡំថា“ជាសកម្មភាពដើម្បីនយោបាយ”នៅឡើយទេ។



លោក កឹម សុខា ទៅចែកអំណោយ



ទឹកលិចនៅពោធិសាត់

ក្រុមហ៊ុនអចលនៈទ្រព្យ អឺប៊ឺន រាលអ៊ីស្តេត
URBAN REAL ESTATE
មជ្ឈមណ្ឌលផ្តល់សេវាជួលលំនៅដ្ឋាន
Residential Leasing Center

ដាញ៉ែល តាន
ភ្នាក់ងារអចលនៈទ្រព្យ
Daniel Tan
Real Estate Agent
Cell: 978-902-6354
508 Westford Street • Lowell, MA 01851
(978) 454-0444

ក្រុមហ៊ុនធានារ៉ាប់រង ខេខេ អ៊ីនសួរិន អេជេនស៊ី
KK Insurance Agency, Inc.
រថយន្ត • លំនៅដ្ឋាន • អាជីវកម្ម
Car • Home • Business

508 Westford Street
Lowell, MA 01851
978-970-2212
kk@kkinsurancema.com

KhmerPost USA, LLC
សារព័ត៌មានខ្មែរផុសសហរដ្ឋអាមេរិក


អគ្គនាយក សុបិន្ត ពិន
Soben Pin, Co-Founder|Publisher
Office: 978 677-7163 | Cell: 978-656-8141
Soben@khmerpostusa.com


និពន្ធនាយកខ្មែរ Khmer Editorial
និពន្ធនាយក ពិន សំខុន
Roger Samkhon Pin, Co-founder|Editor
978-942-8490 | pinsamkhon@gmail.com

ផ្សាយពាណិជ្ជកម្ម សុបិន្ត ពិន
Advertising Contact
Soben Pin
Cell: 979-656-8141
Soben@khmerpostusa.com

អ្នកនិពន្ធកិត្តិយស Staff Writer| Translator
Sokharath Koy | Khmerpostusa@gmail.com
ច្នៃសោភ័ណ្ឌភាព Design Artist
Heng Chhun Leng

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.
Follow us: Facebook | Twitter KhmerpostUSA

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare
### Home Care Agency
Group Adults Foster Care Program

***ហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុម គ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។***

*At no Cost to you*

សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកដោយមិនគិតថ្លៃអ្នកនឹងត្រូវបានថែទាំដោយក្រុមបុគ្គលិកខ្មែរដែលមានវិជ្ជាជីវៈពី នើស (Nurse), Case Manager និង Home Health Aide បុគ្គលិកមានសណ្តានចិត្តល្អ ទន់ភ្លន់ និងមានការគោរពទំនៀមទំលាប់ខ្មែរ ។ បំរើសេវាក្នុងតំបន់ Lowell, Lynn, Revere, Boston និងតំបន់ជុំវិញ





**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**

- *រស់នៅផ្ទះរដ្ឋ*
- *អាយុ ២២ ឆ្នាំឡើងទៅ*
- *មាសហ៊ែលស្តង់ដា*

**ផលប្រយោជន៍ទទួលបាន :**

- *ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ*
- *ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក*
- *ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីជើ*
- *វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់*
- *សមាជិកអាចទាក់ទងមក២៤ម៉ោង*

***To be eligibled for GAFC you must:***

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**

To register, please contact:

Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

# One Door Closed, Another Opens: Welcome Borybo Phearak Boutique & Services to Lowell Cambodia Town

By Soben Pin | Facebook/Twitter@SobenPin

Lowell - the well known Pailin Plaza on Middlesex Street has added a refreshing new store — Borybo Phearak Boutique & Services to its Cambodian identity. The two inspired entrepreneurs, an aunt, Melissa Lahkanna Soy from Lynn and her Lowell native niece Sanya Sum, an English teacher at Samoset Middle school in Leominster had teamed up and opened a Cambodian traditional boutique & service during the Covid-19 pandemic.

Borybo Phearak is the rebirth of Amara Boutique, a well known business established at the Pailin Plaza for over a decade. It was featured in Yankee Magazine as one of the destinations to visit in Lowell Cambodia Town, May 2020 edition. Then the pandemic hit-hard and forced the business to close its door.

"It was our calling" said Sanya. There is nobody traveling right now, and all weddings from this year have been postponed to the next year. There is so much uncertainty of how it will be in the next year. "But if you don't put your feet in the water, you don't know how deep the water is" said Lahkanna. Lahkanna came to the United States as a child refugee when she was 10 years old, living in Seattle, Washington, and her marriage and fate brought her to Lynn in 1996. Since then, she has been a make up artist for Cambodian traditional wedding for the past 20 years. "I love Cambodian culture and a rare opportunity has come", she said.

The two, aunt and niece, dressed up Amara Boutique into its full glory. With a modern look, new hardwood flood, added lights and 100% new design from bottom to top, the Boutique is very appealing to a new generation of shoppers. From the rows and columns of Cambodian men's wear, to women's traditional clothes, sparkling shoes, children's clothing, hair pins, glossy wood sculptures made in Cambodia, the content of the store defines the word Borybo Phearak— means " plenty of stuffs" in Khmer language, a name given by a Khmer Monk with his blessing.

It was off to a good start. Sanya was told by her uncle that she should light five incense a day, every morning when she comes to work. That is the blessing tradition each day for the business. Surrounded by families and friends, the ribbon was cut and champaign bottles popped. "Money, money" someone cheered.




Photo from Left to Right: Sath Soy, Angelina Pop, Hoeun Heng, Sara San, Mellissa Soy, Roeuth San, Roeun Nga, Roeon Soy, Sarin Sang, Leon Pop, Sanya Sum, Anana Bettencourt, Sokha Soy.





Borybo Phearak Co-owners Lahkhana Melissa Soy and Sanya Sum pour the Champaign to make a toast. Photo by Soben Pin





ការិយាល័យ មេធាវី
ថំមាស ស្តាលីយ៉ាណូស

Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766
www.thomasinlowell.com

**PRINT READERSHIP**
*50,000 Monthly / 600,000 Annually*
*Plus additional exposure in our online editions at khmerpostusa.com*

KhmerPost USA

**ONLINE EDITIONS AVAILABLE AT KHMERPOSTUSA.COM**

# 2020 PRINTING SCHEDULES

## EFFECTIVE FEBRUARY 1, 2020

### ADVERTISING RATES AND SIZES

*All ads are printed in Full Color*

| Ad Size (WxH) | 1 Issue<br>5% Savings | 3 Months (6 Issues)<br>7.5% Savings | 6 Months (12 Issues)<br>10% Savings | 12 Months (24 Issues) |
|---|---|---|---|---|
| **Full** (10" wide x 13" tall) | $460 | $2,622 | $5,106 | $9,936 |
| **1/2** (10" wide x 6.5" tall) | 310 | 1,674 | 3,441 | 6,696 |
| **1/4** (5" wide x 6.5" tall) | 165 | 940 | 1831 | 3,564 |
| **1/8** (5" wide x 3.25" tall) | 90 | 513 | 999 | 1,944 |

**Your ad is also published in our online editions of the newspaper at khmerpostusa.com**




### MONTHLY DISTRIBUTION

*70+ Locations in Lowell, MA • 7,000 copies*
*25 Locations in Lynn & Revere, MA • 1,000 copies*
*25 Locations in Providence & Cranston, RI • 2,000 copies*
*Additional distribution online*

### *Khmer Post USA Distribution Locations Include:*

*Households • Markets • Retail Businesses*
*Restaurants • Office Buildings • Government Offices*
*Chamber of Commerce • Buddhist Temple*
*Laundromats • And Much More*

| 2020 PRINTING DATES | ADVERTISING DEADLINE |
|---|---|
| February 15 -Friday | February 13- Thursday |
| February 29 -Saturday | February 28-Friday |
| March 09 -Monday | March 6 - Friday |
| March 23 -Monday | March 20 - Friday |
| April 06 -Monday | April 3 - Friday |
| April 20 -Monday | April 17 - Friday |
| May 04 -Monday | May 1 - Friday |
| May 18 -Monday | May 15 - Friday |
| June 1 - Monday | May 29 - Friday |
| June 15 - Monday | June 10 - Wednesday |
| July 1 - Wednesday | June 26 - Friday |
| July 15 - Wednesday | July 10 - Friday |
| August 1 - Saturday | July 27- Monday |
| August 15 - Saturday | August 10 - Monday |
| September 1 - Tuesday | August 27 - Thursday |
| September 15 - Tuesday | September 10 - Thursday |
| October 1 - Thursday | September 26 - Saturday |
| October 15 - Thursday | October 10 -Saturday |
| November 1 - Sunday | October 27 - Tuesday |
| November 15 - Sunday | November 10 - Tuesday |
| December 1 - Tuesday | November 25 - Wednesday |
| December 15 - Tuesday | December 10 - Thursday |

***Advertising deadlines are 5 business days prior to printing date.***

### CONTACT INFO

**27 Jackson Street • Unit 329 • Lowell, MA 01852**
**Tel: 978.677.7163 • Fax: 978.677.7092**
**Email: khmerpostusa@gmail.com**
**www.khmerpostusa.com**

*Khmer Post USA is a proud member of New England Press & Newspaper Association and Greater Merrimack Valley Convention and Visitors Bureau*

Follow us @KhmerPostUSA

Follow us @KhmerPostUSA